# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះទេពសត្ថា ហួរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| អ្នកឧកញ៉ា ឈឹម - ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជាភាគទី ១ (ត).. | ១៦១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (ត).... | ១៧០ |
| លោក ភិយ-ប៊ុក នាយបញ្ជី | សុភាសិតខ្មែរ ភាគទី ១.............. | ១៨១ |
| — | ប្រជុំពាក្យព្រេងនឹងបាវចនាបារាំងផ្សេងៗ..... | ១៨៦ |
| លោកអាចារ្យ និញ - ប្រាជ្ញ | រឿងធ្វើស្រែខ្មែរ នៅកម្ពុជាក្រោម (កូស័ងស៊ីន) ( ត )........................... | ១៩០ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក ( តមក )............ | ១៩៩ |
| **ផ្នែកសាសនា** | | |
| ព្រះមហា កែវ - ណាគ្រី | មង្គលកុណ្ឌលីនិទាន (ត - ចប់)............ | ២០៩ |
| ឃុន បណ្ណានុរ័ក្ស ប៊ូ - ប៊ុ | វិធីរក្សាចិត្ត ក្នុងបច្ចុប្បន្ន (ត ចប់).......... | ២១៩ |
| **កំណត់ទីនប្រវត្តិការណ៍** | | |
| ព្រះអាចារ្យ ផាម - ណាងបាក | ប្រវត្តិលោកគ្រូចៅអធិការវត្តក្បាលកោះ ...... | ២២៧ |
| ពុទ្ធសាសនបណ្ឌិត្យ | សេចក្តីជូនដំណឹងរឿងបោះពុម្ពព្រះត្រៃបិដក.... | ២៣៦ |


---

ឆ្នាំទី ២១ – លេខ ៣ ខែមិនា ឆ្នាំ ១៩៤៩ – ជំនៀវភាវ ១ ឆ្នាំ ៩៦ រៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî NHOK-THÊM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Satthā So-HAY membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**


| | | page |
|---|---|---|
| Neak Oknha CHHIM-KRASEM Député | Histoire ancienne du Camdodge (suite). | 161 |
| Luong Nibandhamantrî Nhok-Thèm | Histoire sommaire de l'Inde (suite). | 170 |
| M. Ray-Buc chef comptable (I. B.) | Maxime et Pensée ...... ........ | 181 |
| — d.— | Recueil de dictons et des devises français ........................ | 186 |
| Monsieur Dinh-Prach | Travaux des champs chez les Cambodgiens de Cochinchine (suite) ....... | 190 |
| Neak Oknha Vipularāja senā NOU-KAN député | Histoire de "Sam kok" (suite)..... | 199 |


**Partie religieuse:**


| | | |
|---|---|---|
| Brah Mahâ KEO-NAKRI | Matthakundalinidâna (suite et fin)... | 209 |
| Khun Pannānuraks Bou-Po (I.B.) | Entrainement spirituel (suite et fin). | 219 |


**Notes et chroniques**


| | | |
|---|---|---|
| Vén. PHAM-LEANGHA | Biographie du feu Vén. Meas-You... | 227 |
| Institut Bouddique | Communiqué de l'Institut Bouddhique au sujet de la publication du tripitaka | 236 |


21e Année: No 3 Mars 1949 — Prix d'abonnement 96$00 par an.

ព្រះរាជពង្សាវតារភាគទី ១

សម័យ នគរភ្នំ

# ក្រសេម ទេពពិទូរ រៀបរៀង

(តមក)

## ព្រះបាទវីរវរ្ម័ន

ប្រមាណ ព. ស. ៧៤២ - ៧៤៤ គ. ស. ១៩៩ - ២០១

កាលព្រះបាទកុមេរុ អង្គកទីកដសោយទិវង្គត ហើយព្រះរាជបុត្រ ព្រះនាម វីរវរ្ម័ន បានទទួលគ្រងរាជសម្បត្តិតមក, ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេចមិនប្រាកដ មានព្រះរាជបុត្រតូច ៗ ពីរអង្គ ។

ការផែនដី ព្រះមហាក្សត្រិយ៍អង្គនេះ ប្រហែលជាទ្រង់ខ្សោយព្រះសមត្ថភាព ឬពុំដូច្នេះ ក៏ទ្រង់មានព្រះកាយ ទុព្វល មិនធូរ ដល់រាជកិច្ចទាំងពួង ទើបប្រាកដថា ទ្រង់បានប្រគល់សព្វកិច្ចការផែនដីឲ្យសេនាបតីធំ ១ នាក់ ឈ្មោះ ទុំយ (ចិនហៅ ហ្វានចេម័ន) សឹងតាក់ទងជាព្រះរាជវង្ស ជាអ្នកមានសមត្ថភាពទាំងសតិបញ្ញាជ្រៅជ្រះ ទទួលប្រតិបត្តិការស្នងព្រះអង្គ ។ ការផែនដីក្នុងវេលានោះបានចំរើនយ៉ាងណាខ្លះ មិនឃើញមានពោលដល់ ។ ព្រះបាទវីរវរ្ម័នស្តេចស្ថិតនៅក្នុងរាជសម្បត្តិបានតែ ៣ ឆ្នាំ ក៏សោយទិវង្គត ។

# ព្រះបាទឧទ្ទយវរ្ម័ន

ព.ស. ៧៤៤-៧៦៨, គ.ស. ២០១-២២៥,

កាលព្រះបាទឧវវរ្ម័នសោយទិវង្គតហើយ រាជសម្បត្តិត្រូវបានទៅព្រះរាជបុត្ររបស់ព្រះអង្គ តែត្រឡប់ជាបានទៅឧទ័យសេនាបតីឈ្មោះព្រះបរមនាមថា ឧទយវរ្ម័ន ។ ការបានទទួលរាជសម្បត្តិរបស់ព្រះបាទឧទយវរ្ម័ន បើនិយាយតាមច្បាប់រាជសន្តតិវង្សឈ្មោះថាទំលាយសិទ្ធិរបស់ព្រះរាជកុមាររជ្ជទាយាទបុត្រ តែនេះ ប្រហែលជាដោយហេតុព្រះរជ្ជទាយាទនៅកុមារតូចពេក ទាំងដោយហេតុព្រះឧទ័យសេនាបតីមានសមត្ថភាព ធ្លាប់បានទទួលគំនាប់សរសើរ ក្រោមការថែរក្សាពីដំបូងមក ជាទីនិយមរបស់ប្រជាជនទូទៅ គណៈកម្មការរាជសន្តតិវង្ស ក៏ព្រមព្រៀងអញ្ជើញឧទ័យសេនាបតីឡើងសោយរាជ្យ ។ ទ្រង់មានព្រះអគ្គមហេសីត្រូវជាកនិដ្ឋភគិនីរបស់ក្សត្រិយ៍ស្រីមារ (ចាម្ប) នៅក-ព័ន តែព្រះនាមដូចម្តេចមិនប្រាកដ ទ្រង់មានព្រះរាជបុត្រ ២ អង្គ ព្រះនាមហៅតាមសំដីចិនថា ហ្វាន់គិមចេង ១ ហ្វាន់ចាង ១ ។

**ការជីកដី** — ដំបូងទ្រង់ឲ្យប្រមូលពលទាហានជើងគោក ជើងទឹក និងទ្រង់ឲ្យសាងទូកចំបាំងជាច្រើន ទុកសម្រាប់ការពារប្រទេស ។ ក្រោយនោះ ស្តេចបានលើកទ័ពជើងទឹកទៅក្រមាបស្រុកបៀន ១០ ជិតាំង នៅតាមជួរមាត់សមុទ្រសៀម សព្វថ្ងៃនេះ រហូតទៅដល់ពាក់កណ្តាល

ដែនម៉ាលយូ បានស្រុកផាំង ១១ រួមបញ្ចូលជាព្រះរាជអាណាខេត្ត របស់ព្រះអង្គ ស្រុកដែលប្រាកដឈ្មោះក្នុងសេចក្ដីកត់ហេតុ ៩ គឺស្រុក ក្យូចគិន, គិរេង, ទៀនសុិន, ឡង់យ៉ាសុិ, តាមព្រលិង្គ, តាចមិរលៀង, គោះក្រា, ចេជាស និងប៉េរ័ក ។ ស្រុកតាមព្រលិង្គ ប្រាកដក្នុងភាសាមគធៈជា តម្ពលិង្គ គឺជាមណ្ឌលស្រីធម្មនគរ ( នគរស្រីធម្មរាជ ) ។ ចំណែកភាគប៉ែកខាងកើត ទ្រង់បានលើកទ័ពទៅក្រើន ដល់ទៅកើន គឺស្រុកញាត្រាងសព្វថ្ងៃនេះ ។

ក្រោយបំផុត ស្ដេចបានលើកទ័ព ដ៏ធំទៅវាយប្រទេស ១ នៅទិសខាងលិច ចិនហៅ កិងលិង ឬគិមប៉េង ក្បែរព្រំប្រទល់ដែន មាស ធៀបនឹងភាសាមគធៈ ត្រូវនឹងសុវណ្ណភូមិ អ្នកប្រវត្តិសាស្ត្រ កំណត់ថា កិងលិង គឺ ប្រទេសមន តែទ្រង់វាយបានសម្រេច ឬពុំបានទេ មិនប្រាកដ មានតែសេចក្ដីថា ស្ដេចសោយទិវង្គតក្នុងគ្រាទៅធ្វើព្រះរាជសង្គ្រាមនោះ ។ ដោយហេតុទ្រង់បានបំពេញព្រះរាជករណីយកិច្ចពង្រីកព្រះរាជអាណាខេត្តឲ្យធំទូលាយយ៉ាងនេះ តាមឋានៈនៃព្រះអង្គជាខត្តិយៈ ( អ្នកចំបាំង ) ក៏ប្រាកដព្រះកិត្តិយសជា រាជាធិរាជ និងជាក្សត្រិយ៍សឹក ១ អង្គក្នុងប្រវត្តិសាស្ត្រ ។

# ព្រះបាទអាទិត្យវរ្ម័ន

ព. ស. ៧៦៨-៧៨៧, គ. ស. ២២៥-២៤៤

លុះព្រះបាទជ័យវរ្ម័នសោយទិវង្គតហើយ ព្រះរាជភាគិណេយ្យ របស់ព្រះអង្គ ព្រះនាមហៅតាមសំដែងថា ហ្វានចាន់ (ព្រះច័ន្ទ) លបធ្វើឃាតព្រះហ្វានឈិនឆេង ដែលត្រូវទទួលរាជសម្បត្តិបន្ត ហើយក៏ឡើងគ្រងរាជ្យ- ប្រកាសព្រះនាមថា អាទិត្យវរ្ម័ន ។ ស្ដេចមាន ព្រះអគ្គមហេសី នឹងព្រះរាជបុត្រព្រះរាជធីតាប៉ុន្មាន មិនប្រាកដ ។

ការផែនដី: ព្រះបាទអាទិត្យវរ្ម័ន ទ្រង់បានតាំងវរបុរស ១ នាក់ ឈ្មោះស្រីអាជុន ឲ្យជាសេនាឯករបស់ព្រះអង្គមានងារជាព្រះសង្គ្រាម ជ័យ ។ ទ្រង់បានចាត់ព្រះរាជទូត ១ អង្គឲ្យនាំព្រះរាជសារនិងរាជ- បណ្ណាការទៅសុំចងសម្ពន្ធមិត្តនឹងស្ដេចឥណ្ឌាក្នុងវង្សមុរុណ្ឌាស, ស្ដេច នោះបានផ្ញើសេះទេស ៤ ទុកជាបណ្ណាការតបមកវិញក្នុងពេលនោះ ។ ក្នុងឆ្នាំ ព. ស ៧៨៦ ទ្រង់បានតែងរាជទូតឲ្យនាំរាជសារនិងរាជបណ្ណា- ការទៅសុំចងសម្ពន្ធមិត្តនឹងប្រទេសចិន ១ ប្រទេសទៀត ។ ប្រាកដ ក្នុងប្រវត្តិសាស្ត្ររបស់យើងថា ព្រះបាទអាទិត្យវរ្ម័នទ្រង់បានធ្វើនយោ- បាយក្នុងផ្លូវចងសម្ពន្ធមិត្តនឹងនានាប្រទេស ជាដំបូង ។

ក្រោយនោះ ស្ដេចបានលើកទ័ពជើងគោកចេញទៅពង្រីកព្រះរាជ អាណាខេត្តប៉ែកខាងលិចតាមផ្លូវទន្លេមេគង្គ បានទំលាយចេញទៅ

ទៀត តែមិនប្រាកដកន្លែងសេចក្តីពិតហេតុថា បានស្រុកអ្វីខ្លះ ។ តាមផ្លូវសន្និដ្ឋានរបស់អ្នកប្រវត្តិសាស្ត្រ ព្រះបាទសាទិត្យវ័នទ្រង់វាយយកបានរដ្ឋតាក្រុង របស់លក់ ព្រោះរដ្ឋតាក្រុង ទៅជាប់ព្រំប្រទល់ខ្មែរកាតខាងលើនេះ ។ ព្រះមហាក្សត្រិយ៍អង្គនេះ ហើយដែលប្រាកដរឿងក៏នៅសិលាចារឹកកន្លែងស្រុកកាក់ន ។

ព្រះបាទសាទិត្យវ័នស្តេចទៅកន្លែងសម្បត្តិលើមកក្រឹត្យ ព. ស. ៧៨៧ ក៏ត្រូវព្រះហ្វាន់ចាន ព្រះរាជនេស្តេចក្មួយរបស់ព្រះបាទ ។ ទយវ័នលបចូលព្រះជន្មបង់ ដើម្បីយកពជបល្ល័ង្ក ។ តោះបីទ្រង់សោយទិវង្គតដោយការករមិនប្រក្រតីដោយ តែព្រះអង្គក៏នៅមានព្រះកិត្តិយសជាបជាមិតជ ១ អង្គទៀតក្នុងប្រវត្តិសាស្ត្រ ។

# ព្រះបាទស្រីអរជុន

ព. ស. ៧៨៧ - ៨៤០ ? គ. ស. ២៤៤ - ២៩៧

ការដែលព្រះហ្វាន់ចានធ្វើគតព្រះបាទសាទិត្យវ័ន ក៏ដោយបំណងទំនងយកពជសម្បត្តិ តែជាការឥតអំពើ ព្រោះថា ក្រោយនោះ មិនយូរប៉ុន្មានព្រះហ្វាន់ចាននោះ ក៏ត្រូវព្រះស្រីអជុនពិឃាតបង់ទៅទៀត ព្រះស្រីអជុនក៏ឡើងគ្រងបល្ល័ង្កជ្យានព្រះបរមធាម តាមដើមថា ស្រីអ. ជុន ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាមជុបម្កុ ទំនងមានព្រះរាជបុត្រព្រះរាជនទិប្បទេ មិនប្រាកដ ។

ការរីកដី — ក្នុងឆ្នាំ ព. ស. ៧៨៨ ព្រះបាទស្រីអរជុនទ្រង់ទទួលបដិសណ្ឋារៈរាជទូតចិន ឈ្មោះ ខាំងថៃ និងជូលិន និងរាជទូតមុរុ-ណ្ឌាស ដែលមកដល់ព្រមក្នុងពេលជាមួយគ្នា ដើម្បីសូមចងជាសម្ពន្ធមិត្តនឹងប្រទេសខ្មែរ ព្រោះមកតបការទៅនៃរាជទូតខ្មែរដែលបានទៅកាន់ប្រទេសទាំងពីរនោះ ក្នុងរដ្ឋកាលព្រះបាទសាក្យវរ្ម័នមុននេះផង ។ ចិននឹងមុរុណ្ឌាសបានតែងរាជទូតឱ្យនាំរាជបណ្ណាការមកសូមចងសម្ពន្ធមិត្តនឹងប្រទេសខ្មែរក្នុងរដ្ឋកាលនេះជាដំបូង ។ តមក រាជ-ទូតចិនក៏បានមកកាន់ប្រទេសខ្មែរជារឿយ ៗ មកទៀត ដូចមាននិយាយក្នុងពង្សាវតារចិនស្រាប់ ។

ក្រោយពីពេលដែលទ្រង់ទទួលរាជទូតរបស់ប្រទេសទាំងពីរ បានស្ដេចលើកទ័ពហ្វូនទៅក្រោមបដ្ឋាកតិ បានសម្រេចហើយរួមបញ្ចូលមកក្នុងព្រះរាជអាណាខេត្តរបស់ព្រះអង្គ ។ ក្នុងប្រវត្តិសាស្ត្រសាកល (ភាគ ៤) ថា តាំងពីពុទ្ធសតវត្សទី ៨ ជាដើមមក ខ្មែរតែងតែមានអំ-ណាចក្ដិសិទ្ធិខ្លាំងឡើង ៗ ផ្សាយឥទ្ធិពលទៅតាមដងទន្លេមេណាមទៅពេញ (ទន្លេរស្ព) គ្របគ្រងប្រទេសនេះ អស់កាលជាច្រើនឆ្នាំ (៦០០ ឆ្នាំ) ។ ព្រំប្រទល់ប្រទេសខ្មែរភាគខាងលិចគាប់ពីក្នុងរដ្ឋកាលនេះ បានផ្សាយទៅទល់នឹងដែនមន ។

ក្នុងឆ្នាំ ព.ស. ៨១៣ ស្ដេចហ្វាន់ហ៊ាយុន ខរលើនយ៉ (បម្យ៉ា) ទ្រង់តាំងទីនៅភាគទិសខាងកើតប្រាបស្រុកម៉ៃកខាងជើង តែមិនអាចទីនៅលើក ទៅដោយទំនើង ទើបមានព្រះពុទ្ធសាសនា ក្រាបទូលគញ្ចោញព្រះបាទ ស្រីអរជុនលើកកងទ័ពទៅជួយ, ព្រះបាទស្រីអរជុន ទ្រង់លើកកងទ័ព ហ៊ុនទៅជួយដោយព្រះអង្គឯង កាលស្រេចព្រះរាជសង្គ្រាមហើយ ស្ដេច លើកទ័ពត្រឡប់ព្រះនគរដោយសុវត្ថិភាព ។

ប្រមាណមកដល់ក្នុង ឆ្នាំ ព.ស. ៨៤០ ស្ដេចសោយទិវង្គត ។ ព្រះរាជាអង្គនេះ ជាវីរក្សត្រិយ៍ ប្រាកដព្រះកិត្តិយសជា បជាធិកជ ១ អង្គក្នុងប្រវត្តិសាស្ត្រ ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . លង្វែកប្រវត្តិសាស្ត្រ . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

ប្រវត្តិសាស្ត្រតាំងពីផុតរជ្ជកាលព្រះបាទស្រីអរជុន រវាង ព.ស. ៨៤០ ដល់ ៩០០ បានសូន្យទៅ សម្បុកនឹកពង្សាវតាររ៉ង គឺមិនមានពេល ដល់សាររៀបរៀងព្រះរាជពង្សាវតារគ្រានេះ គឺផុតវិស័យនឹងស្រាវជ្រាវ ឲ្យឃើញមកវិញ ទើបសូមផ្ទេរសិក្សាប្រវត្តិសាស្ត្រឲ្យជួយស្រាវជ្រាវ តទៅ ។

# ព្រះបាទចន្ទនៈ

ព.ស. ៩០១ — ៩៦៣ គ.ស. ៣៥៨ — ៤២០

ដល់មកក្នុងឆ្នាំ ព.ស. ៩០០ មានក្សត្រិយ៍ ១ អង្គព្រះនាមចន្ទនៈ ស្តេចមកពីឥណ្ឌា បានឡើងសោយរាជ្យ បានព្រះបរមនាមថា ចន្ទនៈ (ចន្ទវរ្ម័ន) ទ្រង់មានព្រះអគ្គមហេសីព្រះនាមដួងមេត្ត និងមានព្រះរាជបុត្រព្រះនាមជ័យមេឃ មិនប្រាកដ ។

ការផ្សេងៗ: ការវប្បធម៌ ទ្រង់បានចាត់ការយ៉ាងណាបានចំរើនយ៉ាងណាខ្លះ មិនមានដំណឹងជាជាក់លាក់ មានតែថាទ្រង់ជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងស៊ប់ស្ងួន ។ ក្នុងឆ្នាំ ព.ស. ៩៤៦ ទ្រង់បានទទួលគម្ពីរព្រះត្រៃបិដកពីលង្កា គម្ពីរព្រះត្រៃបិដកនេះ ប្រហែលជាគម្ពីរដែលព្រះពុទ្ធឃោសាចារ្យ បានទៅប្រជុំប្រែជាភាសាមគធៈ និងចារដាក់ស្លឹករឹតនៅលង្កាក្នុង ព.ស. ៩៥០ ក្រោយតែការបានមកនេះ ដោយទ្រង់ឲ្យទៅស្វែងរកមក ឬដោយមានអ្នកនិមួយនាំយកមកថ្វាយ មិនមានពោលដល់ ។ ទោះបីយ៉ាងណាក៏ដោយ ការបានព្រះត្រៃបិដកនោះ ជាមង្គលលាភដ៏ខ្ពស់ដល់ប្រជាជាតិខ្មែរ ។ តាំងអំពីនេះទៅ ការព្រះពុទ្ធសាសនាបានចំរើនយ៉ាងណា អាចនឹងឃើញបានក្នុងរជ្ជសម័យនៃព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នឯណោះ ។

# ព្រះបាទស្រីន្ទ្រវរ្ម័នទី ១

ព.ស. ៩៦៣ – ១០១៣, គ.ស. ៤២០ – ៤៧

ក្សត្រិយ៍អង្គនេះ ប្រហែលជាទាក់ទងដោយព្រះរាជវង្សមុនស្ដេច មកពីនគរប៉ាមោ (នៅក្នុងដែនកម្ម័ញ្ញភាគលើ) ពេលព្រះបាទចន្ទនៈ សោយទិវង្គតហើយ ក៏បានឡើងសោយរាជ្យជាតំណាងមានព្រះបរម-នាមថា ស្រីន្ទ្រវរ្ម័ន ពាក់ជាទី ១ ឬហៅថា ឥន្ទ្រវរ្ម័ន ទ្រង់មានព្រះអគ្គ-មហេសីព្រះនាមដូចម្ដេច និងមានព្រះរាជឱរសព្រះរាជធីតាឬទេ មិន ប្រាកដ ។

**ការផែនដី:** ក្នុងផ្លូវរដ្ឋប្រសាសនោបាយ កាលក្នុងឆ្នាំ ព.ស. ៩៧៤-៩៧៨ ព្រះរាជាននគរលិនយ៍ បានផ្ញើរាជទូតឲ្យមកសូមរួតចិត្តរបស់ព្រះបាទស្រីន្ទ្រវរ្ម័ន ដើម្បីនឹងយកទៅវាយនគរលោជីន (នគរគុងកិង) របស់ចិន តែទ្រង់ពុំបានថ្វាយទៅតាមសុំ ។ មកក្នុងឆ្នាំ ព.ស. ៩៧៧-៩៨១ ព្រះបាទស្រីន្ទ្រវរ្ម័នបានផ្ញើរាជទូតឲ្យនាំរាជសារទីងរាជបណ្ណាការទៅសូមចងសម្ព័ន្ធនឹងប្រទេសចិន ។ ព្រះមហា-ក្សត្រិយ៍ប្រទេសខ្មែរបានចងសម្ពន្ធមេត្រីនឹងប្រទេសចិន ជាគ្រាទី ២ ក្នុងរជ្ជកាលនេះ ។ (មានត)

# ប្រវត្តិសាស្ត្រសង្ខេបនៃល្ខោន

## ហង្សទិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

---

កាលវង្សសិសុនាគៈ បានគ្រប់គ្រងដែនមគធៈ រហូតមកដល់ពុទ្ធសករាជ ១៨២ ឆ្នាំ ទើបផ្លាស់កាលវង្សថ្មីជាវង្សនន្ទៈ វង្សនេះក៏មានអំណាចពង្រីកអាណាខេត្តមគធៈចេញទៅទៀតជាច្រើន ជិតអស់មជ្ឈិមប្រទេសទាំងមូល ក៏ប៉ុន្តែប្រវត្តិសាស្ត្រល្ខោនត្រូវប្រែប្រួលផ្លាស់ប្ដូរ ដោយការលុកលុយ ចូលមកនៃព្រះបាទអាលេក្សង់ដ៏មហារាជជាក្សត្រជាតិក្រិក ។

## វគ្គទី ២

## វង្សមោរិយៈ - ព្រះបាទអសោកមហារាជ

ប្រវត្តិរបស់ព្រះបាទអាលេក្សង់ដ៏មហារាជនោះ យើងបានដឹងសព្វគ្រប់ហើយ ដូចមានក្នុងពង្សាវតារក្រិកដែលយើងបានពោលរួចមកហើយ ។ មានអ្នកប្រាជ្ញពង្សាវតារខ្លះ ថាមានក្នុងគម្ពីរព្រះពុទ្ធសាសនា ហៅព្រះបាទអាលេក្សង់ដ្រឺថាអលសន្ទរៈ ជារាជានៃយវនៈ តាមន័យនេះ ក្នុងភាសាបាលីហៅជាតិក្រិកថា យវនៈ តែមានក្នុងគម្ពីរណាខ្លះ មិនប្រាកដ ។

ព្រះបាទអាលេក្សង់ដ្រ៍មហារាជនោះ បានធ្វើកំហ៊ានពួកចូលមកក្នុងឥណ្ឌា កាលពុទ្ធសករាជ ២១៦ ហើយច្បាំងលុកយកប្រទេសឥណ្ឌា បានដោយងាយ ហើយទ្រង់ចូលដល់ស្រុកតក្កសិលា ជាគ្រាដំបូង កាលណោះព្រះបាទអម្ភិក្សត្រក្រុងតក្កសិលា ទ្រង់ចុះចាញ់ព្រមជាចំណុះព្រះបាទអាលេក្សង់ដ្រ៍ភ្លាម ដោយហេតុទ្រង់មានសង្ឃឹមថា ទ្រង់បានទទួលអំណាចព្រះបាទអាលេក្សង់ដ្រ៍ការពាររក្សាឲ្យផុតពីការបៀតបៀននៃប្រទេសជិតខាង ៗ កាលគ្រានោះ មានក្សត្រិយ៍ឥណ្ឌា ១ អង្គ ទ្រង់ព្រះនាមពោរះ ឬពោរុស ទ្រង់មានទទួលអំណាចខ្លាំងពូកែ ៗ កាលព្រះបាទអាលេក្សង់ដ្រ៍ទ្រង់ចូលដល់ក្រុងតក្កសិលា ទ្រង់ឲ្យបោះទ័ពឈប់សម្រាកកំឡាំងពួកទាហានល្មមឲ្យបាត់ការនឿយហត់ទើបមានកំឡាំងរឹងប៉ឹងឡើងហើយ ទើបទ្រង់ឲ្យទៅប្រជុំពួកសិស្សក្មេងៗរបស់អាចារ្យទិសាបាមោក្ខ ក្នុងក្រុងតក្កសិលា មកដេញដោលសួរគិតសួរអំពីផ្លូវទឹកកំឡាំងទ័ពរបស់ដែនដេរ្សង ក្នុងឥណ្ឌា ពាក្យឆ្លើយរបស់សិស្សទាំងនេះ ជាគ្រឿងជួយដឹកនាំផ្លូវឲ្យព្រះបាទអាលេក្សង់ដ្រ៍មហារាជ ទ្រង់ច្បាំងលុកយកប្រទេសឥណ្ឌាបានដោយស្រួល ឯអ្នកដែលតតាំងរបល់ជាច្បាំងធំនោះមានតែ ១ ទេ គឺព្រះបាទពោរះ ឬពោរុស ៗ យើងបានពោលមកក្នុងវគ្គទី ១ រួចហើយថា ឥណ្ឌាក្នុងវេលានោះ ដែនមគធៈ ជាដែនធំមានអំណាចជាងគេទាំងអស់ ហើយខណៈនោះ ពជវង្សនន្ទៈគ្រងរាជ្យដែននោះ ប្រសិន

បើព្រះបាទអាលេក្សាន់ដ្រ៍មហារាជច្បាំងឈ្នះផែនមគធៈ ក៏ល្មមទ្រង់មានសង្ឃឹមថា ទ្រង់នឹងឈ្នះឥណ្ឌាទាំងមូលបាន ។ ខណៈនោះព្រះបាទអាលេក្សាន់ដ្រ៍ ក៏ទ្រង់រៀបចំនឹងវាយក្រុងបាដលីបុត្តដែលជាក្រុងនៃផែនមគធៈ ។ កំពុងតែទ្រង់រៀបចំគ្រោងការនេះ ស្រាប់តែមានសិស្សកំឡោះម្នាក់ឈ្មោះចន្ទគុប្ត ដែលកំពុងរៀនសូត្រនៅស្រុកតក្កសិលា ជាពូជពង្សវង្សក្សត្រិយ៍ផែនមគធៈ ហើយជាអ្នកស្អប់ខ្ពើមពូជវង្សនន្ទៈណាស់ បានចូលទៅគាល់ព្រះបាទអាលេក្សាន់ដ្រ៍ ហើយទូលយកអាសាជួយវាយផែនមគធៈឲ្យបាន ។ ប្រសិនបើស្តេចអាលេក្សាន់ដ្រ៍ទ្រង់ជឿស្តាប់សំដីរបស់មនុស្សនេះហើយ ក៏ទ្រង់អាចវាយយកឥណ្ឌាបានទាំងមូលជាពិតប្រាកដ ហើយពង្សាវតាររបស់ទ្វីបអាស៊ី មានអាការប្រែប្រួលទៅយ៉ាងណាខ្លះនោះ ឥតមានណាទាយត្រូវទេ ។ តែព្រះបាទអាលេក្សាន់ដ្រ៍មហារាជទ្រង់ជឿកម្លាំងរបស់ព្រះអង្គឯងហួសពេក ទ្រង់មានចិត្តសង្ស័យមិនត្រូវការជំនួយ ឬសេចក្តីពន្យល់អំពីអ្នកឯណាឡើយ ដូច្នេះហើយទ្រង់បដិសេធមិនទទួលជំនួយរបស់ចន្ទគុប្ត ហើយទ្រង់ធ្វើការលុកលុយប្រទេសឥណ្ឌាដោយព្រះអង្គឯង លុះដើរទ័ពទៅបានត្រឹមពាក់កណ្តាលផ្លូវមិនទាន់ដល់ក្រុងបាដលីបុត្រផង ស្រាប់តែពួកទាហានរបស់ទ្រង់មិនព្រមលើកទ័ពឲ្យឆ្ងាយជាងនោះទៅទៀត ទើបទ្រង់ឈប់លុកលុយឥណ្ឌា ហើយលើកទ័ពត្រឡប់ថយមកវិញ លុះដើរទ័ព

មកដល់ស្រុកបាប៊ីឡូនក៏ក្ស័យព្រះជន្ម ដូចមានរឿងក្នុងពង្សាវតារ
ក្រិចស្រាប់ ។ ហេតុដែលព្រះបាទអាលេក្សង់ដ្រ មិនអាចវាយលុកយក
ឥណ្ឌាបានហេតុនោះ មិនជាការគួរស្ដាយស្រណោះអ្វីឡើយ
គួរកត់ថាជាព្រេងល្អរបស់ប្រទេសឥណ្ឌាផងរបស់ទ្វីបអាស៊ីទាំងមូល ។
ព្រោះថាបើព្រះបាទអាលេក្សង់ដ្រ វាយយកឥណ្ឌាទាំងមូលបាន មុខជា
ឥណ្ឌានឹងក្លាយទៅជាក្រិច ហើយវប្បធម៌ឥណ្ឌាមុខជានឹងសាបសូន្យ
ទាំងពុទ្ធសាសនានឹងលែងចាក់ឫសទៅក្នុងគ្រានោះ ព្រោះនឹងមិនមាន
ព្រះបាទអសោកមហារាជ ទ្រង់ប្រកាសផ្សាយព្រះពុទ្ធសាសនាចេញ
ទៅនានាប្រទេស ដែលយើងនឹងពោលតទៅខាងមុខនេះ ។

ទុកជាយ៉ាងណាក៏ដោយ ការដែលព្រះបាទអាលេក្សង់ដ្រលុកចូល
មកឥណ្ឌានេះ ក៏បាននាំយកវប្បធម៌របស់ក្រិចចូលមកព្រោះព្រាយនៅ
ឥណ្ឌាជាច្រើនដែរ ហើយនៅមានទុកគំនិតសំខាន់មួយទៀតដល់ពួក
ឥណ្ឌា អំពីការធ្វើចម្បាំងលុកយកផែនដីផ្សេងៗ ដើម្បីតាំងខ្លួនជាម្ចាស់
លោកឬជាស្ដេចចក្រពត្តិ ។ មនុស្សជាតិឥណ្ឌាដំបូង ដែលរៀន
យកតំរាប់របស់ស្ដេចអាលេក្សង់ដ្រនេះ គឺចន្ទ្រគុប្តនោះឯង ដែលជា
បឋមកវង្សរបស់ព្រះបាទធម្មាសោក ។

តាំងអំពីកាលដែលព្រះបាទអាលេក្សង់ដ្រលើកទ័ពទៅវិញហើយ
ចន្ទ្រគុប្តក៏គិតគូរតែងតាំងខ្លួនឡើងជាចៅហ្វាយលើប្រទេសឥណ្ឌា

មនុស្សមានចំណេះចេះដឹងល្អ តាំងក្លាហានអង់អាចរឹងប៉ឹង កាលព្រះបាទ
អាលោកស្រីជ័យ ក្រោយព្រះជន្មទៅនោះ ពួកមេទ័ពមេកងដែលរក្សាដែនដី
ដណ្ដៀតាន់ព្រះនេត្រព្រះករុណារបស់ទ្រង់ ក៏កើតវិវាទតស៊ូនឹងគ្នាឯង
ទៀត ទើបប្រទ្ធុតរួបរួមពលចម្បាំងតាំងជាធំទាហានទៀតក្នុងដែន
បញ្ចាប ហើយក៏ចាកពួកមេទ័ពទ្ធរបស់ស្ដេចអាលោកស្រីជ័យចេញបាន
កាលបានរួបរួមកម្លាំងទ័ពបានល្មមសមគួរហើយ ក៏លើកចូលមកក្នុង
ដែនមគធៈ ហើយបង្កការចលាចលទៀត នៅទីបំផុត ក៏កំចាត់កងវង្សនន្ទៈ
ចេញបាន ហើយតាំងខ្លួនជាអ្នកគ្រប់គ្រងដែនមគធៈទៀត កាលពុទ្ធ.
សករាជ ២២៨ ។ ចំណែកឯពួកមេទ័ពរបស់ព្រះបាទអាលោកស្រីជ័យ
ក៏នៅតែមិនចាប់ឈប់រំពងគ្នា ប្រទ្ធុតក៏យកឱកាសនេះពង្រីកដែនមគធៈ
ដោយចម្បាំងលុកលុយបានរហូតដល់ដែនគន្ធារៈ ធ្វើឲ្យអាណាចក្រមគធៈ
រីកធំទូលាយចេញទៅយ៉ាងសំបើម ដែលមិនចាប់ខាតក្សត្រអង្គណា
ក្នុងដែនមគធៈនេះ ពង្រីកអាណាខេត្តចេញទៅដល់ប៉ុណ្ណោះឡើយ ។
ឯពួកក្រិកដែលនៅគ្រប់គ្រងតាដែនដណ្ដៀខ្លះនោះ ក៏ខំព្យាយាមលុប
លាងអំណាចប្រទ្ធុតៈដែរតែមិនសម្រេច នៅចុងក្រោយបំផុត ពួកក្រិក.
ទិញចប្រទ្ធុតក៏ព្រមឲ្យបំជាមិត្រៈមេត្រីនឹងគ្នា ប្រទ្ធុតក៏ទទួលអគ្គកដទូតក្រិច
នៅក្រុងបាដលីបុត្រ ។

កាលវេលាដែលព្រះបាទចន្ទគុប្តមហារាជ ទ្រង់កាន់តាំងឡើងនេះ ហៅថាវង្សមោរិយៈ បានគ្រប់គ្រងដែនមគធៈជាវេលា ៨៤ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ២២៨ ដល់ពុទ្ធសករាជ ៣១២ មានមហាក្សត្រគ្រងរាជ្យ ២ អង្គ ទ្រង់ព្រះនាមព្រះបាទពិន្ទុសារៈដែលជាព្រះរាជឱរសរបស់ព្រះបាទចន្ទគុប្ត គ្រងដែនមគធៈជាវេលា ១៨ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ២៥២ ដល់ពុទ្ធសករាជ ២៧០ ទ្រង់បានលុកលុយដែនទក្ខិណាបថដល់ខេត្តមទ្រាស ហើយនៅត្រង់ស្ពានមេត្រីរវាងឥណ្ឌានិងក្រិក ក៏កាន់តែជិតជិតប្រសើរឡើង លុះដល់មកក្សត្រគ្រងរាជ្យក្រោយៗ មកទៀតដែនម៉ាសេដ្វាន ស្រុកក្រិកក៏បញ្ជូនរាជទូតមកក្រុងបាដលីបុត្រក៏មានៗ

កាលព្រះបាទពិន្ទុសារៈទិវង្គតហើយ អសោកកុមារជាព្រះរាជឱរសក៏បានគ្រងរាជសម្បត្តិព្រះវង្សមគធ ។ ឯព្រះបាទពិន្ទុសារៈនេះមានព្រះរាជឱរសជាច្រើនអង្គ ចំពោះអសោកកុមារ ព្រះរាជបិតាទ្រង់ទតឃើញការប៉ិនប្រសប់តាំងពីនៅជាកុមារ ទើបទ្រង់តាំងឲ្យធ្វើជាឧបរាជ ដំបូងទ្រង់ត្រូវគ្រាប្រចាំនៅស្រុកតក្កសិលា ហើយក៏មកទ្រង់មកប្រចាំនៅស្រុកមាលវៈ ក្នុងកាលដែលព្រះបាទពិន្ទុសារទើបទ្រង់ទិវង្គតនោះ ទ្រង់ក៏សព្វព្រះហឫទ័យរើសអសោកកុមារឲ្យឡើងសោយរាជ្យជាជំនួសព្រះអង្គ ។ លុះមកដល់ឆ្នាំពុទ្ធសករាជ ២៧៦ ទើបព្រះបាទអសោកឡើងសោយរាជសម្បត្តិគ្រងដែនមគធៈ គឺជាវេលា ៦ ឆ្នាំ

ក្រោយព្រះបាទពិន្ទុសារទិវង្គតទៅ មានសេចក្ដីដំណាលថា ហេតុដែលយឺតយូរក្រុបានសោយរាជ្យដូច្នេះ ព្រោះតែគេមិនសះស្រុលនឹងព្រះអនុជទាំងព្រះជេដ្ឋា ជាទំនងដណ្ដើមរាជសម្បត្តិគ្នា ដូចមានក្នុងមហាវង្សតានិយាយថា ព្រះបាទអសោកទ្រង់ផ្ដាច់ព្រះជន្មព្រះអនុជទាំងព្រះជេដ្ឋារបស់ទ្រង់ចោលទៅ តែការសេចក្ដីដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្របានស្រាវជ្រាវគេឃើញនោះ ត្រឡប់ជាមានសេចក្ដីប្រាកដថា ព្រះបាទអសោកមហារាជ ទ្រង់ទំនុកបំរុងផងលៀងព្រះអនុជទាំងព្រះជេដ្ឋាដោយល្អ ឥតមានចោរប្រទូស្តរ៉ាយអ្វីឡើយ ។ ព្រះបាទអសោកមហារាជនេះ ទ្រង់ជាអ្នកមានលក្ខណៈរឹងប៉ឹងធ្វើការដាច់ស្រេច ម៉ឺងម៉ាត់ តែមិនមែនជាក្សត្រកាចសាហាវដូចមានសំដែងក្នុងគម្ពីរខ្លះនោះទេ ។ ពិតមែនតែព្រះបាទអសោកមហារាជទ្រង់ធ្វើសឹកសង្គ្រាមច្រើនក៏ជារឿងធម្មតារបស់មហាក្សត្រគ្រប់ៗអង្គ ដែលត្រូវការស្វែងរកអំណាចផ្សាយទេជានុភាពព្រឹទ្ធការណ៍តែរបស់ព្រះអង្គ ។ ឯព្រះបាទអសោកមហារាជនេះ ទ្រង់ប្រកបដោយរិទ្ធិអំណាចយ៉ាងធំសំបើម ១ អង្គក្នុងពង្សាវតាររបស់លោក ។ រាជអាណាចក្ររបស់ព្រះបាទអសោកមហារាជនោះ ធំទូលាយសំបើមណាស់ជិតគ្របអស់ដែនឥណ្ឌាទាំងមូល គឺក្រៅពីទ្រង់មានអំណាចគ្របដែនដីរបស់អរិយកៈទាំងមូលហើយ នៅបានដែនដីជិតខាងរហូតមកដល់ទន្លេគង្គាផង ។

ក្រៅអំពីការផ្សាយអំណាចពង្រីកអាណាខេត្រ ដែលជាព្រះរាជ-
កិត្តិយសចំពោះព្រះអង្គហើយ ព្រះអង្គទ្រង់ផ្សាយព្រះពុទ្ធសាសនា
ដែលជាកិត្តិគុណដល់ទ្វីបអាស៊ីស្ទើរតែអស់ ១ ទ្វីបផង ។ យើងដឹង
ច្បាស់ហើយថា ដែនមគធៈនោះជាកន្លែងដែលព្រះពុទ្ធសាសនាបាន
ប្រតិស្ឋានចុះជាដំបូងហើយគេគោរពរាប់អានគ្នាមករហូតអស់រាជវង្សនន្ទៈ ។
តែកាលដែលចន្ទ្រគុប្ត បានឡើងគ្រប់គ្រងដែនមគធៈនោះ សាសនា
ព្រាហ្មណ៍បានឡើងជាសាសនាប្រចាំអាណាចក្រមគធៈ ព្រោះហេតុ
ចន្ទ្រគុប្តមានគ្រូបាអាចារ្យជាព្រាហ្មណ៍ ហើយការដែលចន្ទ្រគុប្តតាំង
ខ្លួនជាក្សត្រគ្រប់គ្រងដែនមគធៈបានដោយសារការទូន្មានប្រៀនប្រដៅ
នៃព្រាហ្មណ៍ជាអាចារ្យនុះឯង ។ មួយវិញទៀត ក្នុងសម័យពុទ្ធកាលក្ដី
ក្នុងសម័យក្រោយពុទ្ធកាលក្ដី ព្រាហ្មណ៍តែងមានដំណែងជាបុរោហិត
(គឺទីប្រឹក្សាផងការផែនដី) ហើយធ្លាប់ប្រកាន់មកថា មានតែពួក
ព្រាហ្មណ៍ទេ ដែលចេះដឹងខាងវិជ្ជាអក្សរសាស្ត្រ ឬដែលហៅថា ប៉ូលី-
ទិកឬវិជ្ជាសាស្ត្រនយោបាយ ។ ព្រះបាទពិន្ទុសារជាព្រះជនករបស់ព្រះ
បាទអសោកមហារាជ មានសេចក្ដីជ្រះថ្លាខ្ជាប់ខ្ជួននឹងលទ្ធិសាសនា
ព្រាហ្មណ៍ មានបួនកាល បានអញ្ជើញពួកព្រាហ្មណ៍ឲ្យចូលមកគាល់ក្នុង
ព្រះរាជវាំង មានចំនួនដល់ ១ ហ៊ឺន ៦ ពាន់នាក់ក៏មាន ។ សូម្បីព្រះបាទ
អសោក កាលនៅពីកុមារក៏ទ្រង់សិក្សារៀនសូត្រក្នុងសំណាក់របស់

ព្រាហ្មណ៍ដែរ លុះមកដល់ឆ្នាំពុទ្ធសករាជ ២៧៩ ទើបទ្រង់ប្រកាសព្រះអង្គជាពុទ្ធមាមកៈ ដោយសេចក្ដីណែនាំរបស់មន្ត្រីព្រះអង្គម្នាក់ឈ្មោះឧបគុប្ត ។ ការដែលទ្រង់បែរមកកាន់ព្រះពុទ្ធសាសនានេះដោយទ្រង់ជ្រាបច្បាស់ថា ព្រះអង្គទ្រង់ធ្វើការចម្បាំងកំដែលនាំឲ្យកើតសេចក្ដីគោកហ៊ោតលំបាកវេទនាជាច្រើនក្រៃពេក សេចក្ដីសង្វេគនេះកើតឡើងកាលទ្រង់ច្បាំងបានដែនកាលិង្គៈ ដោយសង្គ្រាមគ្រានេះសាហាវណាស់ បានបំផ្លាញជីវិតមនុស្សច្រើនលើសលន់គណនា ។ កាលពុទ្ធសករាជ ២៩៤ ស្ដេចយាងទៅនមស្ការទីប្រសូតិរបស់ព្រះពុទ្ធជាម្ចាស់ ក្នុងឆ្នាំពុទ្ធសករាជ ៣០៣ ទ្រង់ឧបសម្បទជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។

សង្គ្រាមដែលព្រះបាទអសោកមហារាជ ទ្រង់ធ្វើនៅដែនកាលិង្គៈនោះ ជាសង្គ្រាមធំ ដែលជាមហេតុផ្លាស់ព្រះទ័យព្រះបាទអសោកអំពីអគ្គចម្បាំងមកជាអគ្គធម៌ សិលាចារឹកដែលបានចារឹកព្រះរាជឧត្តររបស់ព្រះអង្គសឲ្យឃើញថា ទ្រង់មានព្រះទ័យសង្វេគជាខ្លាំង ដូចមានសេចក្ដីប្រែខាងក្រោមនេះ :

« សម្ដេចព្រះករុណាជំមានរិទ្ធិ ទ្រង់មានជ័យជំនះដល់ដែនកាលិង្គៈ កាលទ្រង់ឡើងគ្រងរាជសម្បត្តិបាន ៨ ឆ្នាំ ទ្រង់បានចាប់ឈ្លើយចំនួន ១ សែន ៥ ហ្មឺននាក់ ហើយបានសម្លាប់ចោល ១ សែននាក់ » ។

«កាលបានរួមដែនកាលិង្គៈមកក្នុងព្រះរាជអំណាចហើយ ព្រះករុណាដ៏មានឫទ្ធិ ទ្រង់ចាប់ផ្ដើមជាអ្នកគ្រប់គ្រងរក្សាធម៌ ទ្រង់សព្វព្រះហឫទ័យក្នុងធម៌ ទ្រង់សព្វព្រះហឫទ័យទូន្មានធម៌ ហើយរឿងដែលនាំឲ្យព្រះករុណាទ្រង់ទោមនស្សជាខ្លាំងក្នុងការដែលវាយយកដែនកាលិង្គៈ ព្រោះការយកស្រុកនោះរមែងមានការប្រទូស្តរ៉ាយ ឬសម្លាប់មនុស្ស ឬត្រូវចាប់ជាឈ្លើយដែលជារឿងធ្វើឲ្យព្រះករុណាទ្រង់ទោមនស្សព្រះហឫទ័យជាពន្លឹក» ។

តាំងពីព្រះអង្គទ្រង់ប្រកាសជាពុទ្ធមាមកៈហើយ ក៏ទ្រង់ធ្វើការផ្សាយនៃដែលលោកត្រូវទទួលកប់រងថា ព្រះអង្គជាអគ្គពុទ្ធសាសនូបត្ថម្ភកដ៏ពិតប្រាកដ បានទ្រង់កសាងព្រះស្តូប ៨ ម៉ឺន ៤ ពាន់ទៀតក្នុងកជត្រៈ តាំងពីនោះមកក្រុងពជត្រៈក៏ផ្លាស់ឈ្មោះជាក្រុង «វិហារ» ព្រោះជាលំនៅនៃព្រះស្តូបមកដល់សម័យនេះហៅថា «ពិហារ» ។

ក្នុងសម័យរបស់ព្រះបាទអសោកមហារាជ ពួកព្រាហ្មណ៍ អស់ពន្ធីរស៊ី អំពីដើមមក ពួកព្រាហ្មណ៍ធ្លាប់បានទទួលប្រាក់ចំនួកបំរុងរបស់រដ្ឋបាល ដល់សម័យនេះត្រូវកាត់ចេញអស់ ហើយយកប្រាក់នេះទៅចំនួកបំរុងព្រះសង្ឃពុទ្ធសាសនាវិញ ។

ទុកជាព្រះបាទអសោក ទ្រង់យកព្រះហឫទ័យទុកដាក់ក្នុងការ ប្រកាសព្រះពុទ្ធសាសនាជួបប្រះហើយក៏ដោយ នៅក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ ក៏នៅមានសាសនាដទៃ ៗ ទៀតជាច្រើន ។ ព្រះបាទអសោកទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាយ៉ាងមុឺងម៉ាត់ តែមិនដែលប្រទូស្តរ៉ាយសាសនាដទៃ ៗ ទៀតទេ ។ ហើយទុកជាទ្រង់លះបង់សាសនាព្រាហ្មណ៍ចេញពីតំណែងសាសនាប្រចាំអាណាចក្រហើយក៏ដោយ ក៏នៅតែត្រូវការព្រាហ្មណ៍សម្រាប់ធ្វើពិធីផ្សេង ៗ ពុំដែលខាន ផ្សែងពួកដែលកាន់សាសនាព្រាហ្មណ៍ក្នុងវេលានោះ មានចំនួនមិនមែនតិចជាងពួកពុទ្ធសាសនិកជនទេ ។ ម្យ៉ាងវិញទៀត តាំងអំពីបុរាណកាលមកក្តី ក្នុងសម័យនេះក្តី បេះដូងរបស់ឥណ្ឌា នៅក្នុងសាសនា ប្រសិនបើទ្រង់ផ្តួលរំលំសាសនាព្រាហ្មណ៍ទៅ មុខជាកើតចលាចលពុំខាន ។

(មានត)

(1)

សុភាសិតភាគទី ១

# លោក ប៉ិយ-ប៊ុក រៀបរៀង

## ១ — ជាតិវគ្គ

១- ប្រែកាយកែចិត្ត ប្រែលោភទិត ប្រែជាតិសាសនា ប្រែកតញ្ញូមិត្តខួច ប្រែធម៌ប្ដូរ ប្រែមារយាទកិរិយា កាត្តាំបើន ។

២- មនុស្សច្រើនពាក្យតលុងមិនបានការ មនុស្សម្នាក់ប្រាជ្ញាវិសេសឯក អាចរំលើកខ្មាសគ្រប់លើសេក ទំលាប់ធម៌ថ្លៃៗ ប្រែសៅប្រាណ ។

៣- ខ្សោយចំណាំង ខ្ទះប្រែសបង់ប្រាំង ឥឡូវកក្សត្រ ប្រទេសគ្រប់ភាព បង់លោកសីតុល្យ ខ្ទមបាន្ត្រី បង់នៅលើលោក ។

៤- សាមគ្គីមនុស្សកំឡាំងធំពិត សាមគ្គីបណ្ឌិតកើតវិទ្យា សាមគ្គីកស្ត្រីញាតិមិត្តសុខ មន្ត្រីពាលាមិនហ៊ានប្រមាថ ។

៥- គួរយកខ្ញុំធ្វើជាច្បាប់ប្រាណ ពួនជែកស្នាមកំពោតនៃ បះប្រែ៖ បាយក្នុងប្រទៃ ជើងដៃលោតម្ដងស្រាប់បានការ ។

៦- ណាស់កុំយកជាគ្រូ ល្អណាស់ខ្ចីចំណាំ បង់ណាស់មិនប្រាថ្នា លាមកណាស់ធរវិនាសបង់ ។

៧- ធ្វើប្រែសាសបោបាយខ្ញុំបងរក សានជាតិខ្ញុំបន្ទុកនិងប្រកែក ខ្ញុំបានទៀតព្រួយប្រាណបង់បានប្រាក់ ស្រោចទឹកឈើក្រាក់បង់បានផ្លែ ។

៨ - ភ័យអ៊ីមិនស្មើនឹងជាតិភ័យ ក្មេងនេះប្រល័យយកឲ្យភ័យអនេក
វដ្ដៈសង្សារភ័យចំរៀក សព្វនាទីចែកក្បាលពេញប៉ុល ។

៩ កាំភ្លើងធំជាច្បាប់បង្ក្រាបលោក ធ្វើបាបជនក្នុងលោកច្បាប់តំរួន
ព្រហ្មវិហារជាច្បាប់មនុស្សកល្យាណ វិន័យក្សាមានច្បាប់ព្រះរដ្ឋ ។

១០ - ទង់ជ័យជាតិខ្មែរប្រាសាទ បូរខ្មែរសង្ហាតឲ្យដល់ត្រើយ
ព្យាយាមរក្សាកុំគោះគើយ ឃើញហើយលើកដៃគោរពភ្នាម ។ គិតគួ
គោរពក្ដកម្ពុជា ទឹកដីសាសនាពាំងរូបនាម ប្រុសស្រីក្មេងចាស់លោហិត
ឈាម ប្រឹងប្រែងព្យាយាមទំបូជា ។ ស្ថាប់ក្រោមទង់ជ័យពេញគន្ធប្រុស
ហៅស្ថាបចិត្តស្មោះទឹងការ ចំពេញកិច្ចខ្ទខជាអ្នកជា ជាតិជាភាសាគួរ
ស្ងប់ខ្ទម ។

១១ - បើខ្លួនក្នាឲ្យដល់កុន បើផុនអ្នកខ្ទឹនឲ្យដល់ផាក បើវៀន
កវីនិវ្វាក ព្យាយាមសង្ហាតគុណលើ ។

១២ - ពលរដ្ឋសោភ័ណ ព្យាយាមតែប្រាំ ធ្វើការក្លាហាន
សុចរិតសច្ចៈ យកច្បាប់ប្រធាន ប្រើសតិបាន ល្អមប្រាណគ្រប់ ។
បេះរៀបបេះចំ ប្រឹងប្រែងរះរំ សាងជាតិឈ្លាយឈ្លប់ ស្រឡាញ់ទាក់-
ទម្ម៉ សាសនាប្រាព្ធ ចំណងថ្ងៃយប់ ដួយជាតិពាតល្អិត ។ ស្រឡាញ់
ភាសា អក្សរខ្មែរជាតិសាសន៍វិចិត្រ សព្វទំនួត ប្រាព្ធទំនិត
តាំងចិត្តពិនិត្យ ទូរជាតិសាសនា ។

១៣ - កំពូលតិរិកយោធ្វាន ព្រះសុរិយាចាំងក្តៅកាក្លា តែត្រូវរងដោយបក្ខពាសរះ សាងផមិលោកាធាតុភូមិ ។

១៤ - ព្រៃក្បៅព្រៃនៅគ្នងព្រោះបពុតា តែងកាប់ប្រាជ្ញាធាបសប្រែម ត្រជាក់បាំសជ្រះផលឥតទោសភ័យ មនុស្សវិស័យឥតសោកសោកតំខិត ។

១៥ - សាងជាតិឥតពល ធ្វើស្មេចឥតកល់ ពស្រុតាមសាមគ្គី ប្រទេសមនុស្សគិត ឈ្មោះដណ្ដើមទី លង់លិចពារ៍ វិនាសជាតិបង់ ។

១៦ - ទោយយប់នៅសែង ខ្ទមយប់មត្តឯង ជើយប់គេខ្វង់ ជាតិយប់ប្រែសរគ្គ លោកយប់ព្យាប់ព្យួរ ប្រទេសយប់ពួកគង ទើបធ្ងន់ផល់ក្រោយ ។

១៧ - ពុទ្ធធម៌សន្សំក្រៃ ជាតែប្រែពៃ លើសលៃងលោកា សាសន៍ជាតិខឹងក្សែត្រ នោះពស្នេហា ជាប់ជួនហាទយា កុំភ្លេចខ្ទួច ពោះ ៗ ជាតិខឹងកាសា ជាតែគ្រោគា ណាកូនស្រីប្រុស ប្រុសធម្មហាត់ចិត្ត ស្នេហ៍សុទ្ធឲ្យស្មោះ ទុំផាតែវ្ចុះ ពំនាក់ត្រប់ប្រាណ ។

១៨ - ប្រាសាទអង្គរគេក្រពុកណា ត្រូវឲ្យគលប្រាណជាតិស្វស្តិ ចំពើង ក្តាកកថាសៅ ក្រឡប់ផែនដីកពាក ៗ ខគរវត្តជាពស្តុកាងអំណាច ទេមរៈប្រាជ្ញសិល្បវិទ្យា ពីកាលសម័យបុរាណសក្តា គាស្ស្រទេមកគង់ បច្ចុប្បន្ន ៗ ត្រូវក្រុមសេជាតិប្រាក្សត្រ រៀនព្រៃគេចាត់បង់ក្រែងគង់ ដិតដល់អំណាចបុគ្គលមធ្យម គយគន់ថៃខ្មែរប្រែប្រួល ។

១៩ - មន្ត្រីកុំបំបាត់ ខិទ្រាកុំបៀត ស្តេចកុំបំបាយ ត្រូវសេចក្ដីកុំសេចក្ដីព្រាយ បានលាភសប្បាយ កុំបំពានគ្នា ។

២០ មើលឃើញច្រើនចល់ ទោះកុំឆ្ងល់ គួរសេពមេត្រី អ្នកដើរច្រើនស្រុក ទោះបែបមកថ្មី កមកវិស័យ ប្រែខ្លួនទាន់លោក ។

២១ - ធ្វើការស្គាល់កាល ភារៈធ្ងន់ស្រាល ថ្លឹងឲ្យយល់ជាក់ ពលាសទោស គិតគូរធ្វើមគ្គ បានផលតាមថ្នាក់ វិរិយៈសម្រេច ។

២២ - ធម្មតាចង្កឹះមួយកាច់ស្រួលងាយ ចង្កឹះបាច់ទំនាយកាច់ លំបាក មនុស្សមួយងាយធ្វើឲ្យប្រាសចាក មនុស្សច្រើនតាតវ៉ៃ តង់សរសៃ ។

២៣ - លេខមួយមានឆ្នាំនាក់មិនបាន ចរនេះជាស្ថានពិតារណា មិនងាយបានស្រួលក្នុងលោកា ទូបមួយសុរិយាឆ្នាំនេះក៏បុ ។

២៤ - ត្រូវវ័យឲ្យស្ទួរគ្នាបាន វ័យទី ១ ប្រាណធ្វើអ្វីៈ ចម្រើន វិទ្យាលោកធម៌មនុស្ស វ័យទីពីរស្មោះចំរើនជាតិ ។ វ័យទីបីចំរើនផ្លូវ សាសនា កុំកុំបកគ្នាប្រាជ្ញពាល ស្លូរស្ទួរខ្លួនឯងតាមក្បួនខាត ប្រាជ្ញ ក្រៀវក្លាគច្ចង់សង្សារ ។

២៥ - អ្នកលូង់ត្រូវរៀនពីអ្នកនេះ ចង់បានចំណេះត្រូវស្ដាប់គិត យល់ព្រះធិញ្ញាណហាត់រូបចិត្ត បើជាតិនឹងគរត្រូវច័ប ។

២៦ - ត្រាប់ណើក្ខនជី យប់ល្ងិតប្រែស័យ ទំរើបត្រាស ចាល់ ឃើញអាកា សុំយោគ្គីបក្រាស់ ទ្រព្យខ្លួនបង់លះ សាងជាតិសាសនា ។

២៧ - កុំត្រាប់កុកសត្វនទបាយ ឲ្យត្រាប់ព្រាជព្រាយសត្វកុច សាប់ កេសុំកៀនកោះជោយព្រៃស្មាប់ លាក់ខ្លួនខ្លាចស្លាប់គ្មាន ប្រមាទ ។

២៨ ផលាវុក្ខាខ្ពីចង់ចុំ ឥតបុណ្យសន្សំចង់បានស័ក្តិ ឥតទិស្ស័យ អប់រំចង់ស្តេចច័ក្រ ឥតទ្រព្យមាសប្រាក់ចង់សាងជាតិ ។

២៩ សត្វស្មោញត្នូរត្រាប់ លោកទុកជាច្បាប់ សណ្តាប់គាត្នា កុំត្រាប់ផ្តកស្រុក នៅក្នុងទ្រនំមារ ផល់ពេលប្រហារ ទើបដឹងខ្លួន ស្លាប់ ។ បក្សទទា ជាប់ទ្រនំត្រោ នៅតែសួរស័ព្ទ ដើរលេ ឈ្មាតរក ដុំទ្រនំចំកចាប់ ខ្វះខ្វង់ក្រនស្លាប់ រកបន្ទោះបេញ ។

៣០ - ផ្ទៃលោកយកផលពីលើច្បាប់ ផ្ទៃធម៌ប្រាវព្វច្បាប់លើផល ប្រាជ្ញាឥស្សរៈប្រើឃោបល់ ដំកល់ប្រាជ្ញាស្គាល់គិច្ចការ ។

៣១ - ជនណាមានជាតិព្រហ្មភាសា ក្តេបជាតិឥត្តាភាសាខ្លួន ដូចមេអំបោវក្តេបផ្ទៃក្បួន គាប់ចួនចូលវង្សតិរច្ឆានសត្វ ។

៣២ ត្រូវស្រឡាញ់មាតុភូមិលើសជីក ត្រូវហានក្លាមិនខ្លាច ស្លាប់ជួយជាតិបាន ជាតិទុំពេលនាំកន្ទុលវិនាសប្រាណ ឥតមាននក្បាន្ត មានតែខ្សោយហើយលិចលង់ ។ (មាតត)

ប្រជុំពាក្យបាវចនា

Recueil de Dictons et des devises françaises

លោក ក៉យ ប៊ុត ប្រែ លោក ញ៉ុក-ថែម ពិនិត្យកែ

A) Vieilles devises

---

## ក. — ផ្នែកពាក្យបាវចនាបុរាណ

1 — A droit aller nul ne trébuche

១ - គ្មានច្បាប់ហាមឃាត់ទេ ដើរទៅ ។

« បើចិត្តចង់ទៅ ត្រូវចេះតាមផ្លូវ មិនមានហាមឃាត់ ប៉ុនប៉ង សំដៅ ដើរដោយប្រយ័ត្ន គង់ដល់ទីថ្កាត់ ដូចចិត្តប្រាថ្នា » ។

2 — Dieu aide qui s'aide —

២ - ព្រះជួយអ្នកដែលជួយខ្លួន

« ខ្លួនត្រូវជួយខ្លួន ពាក្យនេះជាក្បួន ប្រាប់ចង់ចាំ ការប្រឹង ខ្លួនឯង ថែទាំដឹកនាំ ប្តូរប៉ែរណែនាំ ទើបបានដល់ត្រើយ » ។

3 — La lenteur avance souvent plus .

៣ - សន្សំ ៗ ជឿនទៅមុខជានិច្ច

« ដំណើរសន្សំ កិច្ចការចំណុំ ដើរសព្វប្រាណ គេឲ្យផញ្ចើង រំពឹងវិរិយាន សព្វគ្រប់កម្មឋាន ទើបបានដល់ត្រើយ » ។

4 — Ni trop, ni trop peu —

៤- កុំច្រើនពេក, កុំតិចពេក

« ច្រើនហួសប្រមាណ លុះលើសខានប្រាណ មិនកើតផលា ឯត្រង់តិចពេក ផ្ទុកខ្ជិលធ្វើការ ក៏ខូចអសារ សាបសូន្យប្រយោជន៍ » ។

5 — Mort l'honneur, morte la race
ស្លាប់កិត្តិយស, ស្លាប់ជាតិ

« រក្សាកិត្តិយស រក្សាកេរ្តិ៍ឈ្មោះ ទើបជាតិសាសនា យើងបាន ថ្កុំថ្កើង បើមិនរក្សា កិត្តិយសមរណា ជាតិក៏មរណ៍ » ។

6 — Où tu dois —
កន្លែងណា ឯងក៏ត្រូវតែបំពេញកិច្ចរបស់ឯង

« បំពេញកិច្ចខ្លួន បទបានជាក្បួន កុំឲ្យភ្លេចសោះ របនាខ្លួនបាន ទើបតែចំពោះ ជាតិឲ្យខ្ពង់ខ្ពស់ នាឋានមនុស្សលោក » ។

7 — Qui veut peut —
អ្នកដែលប៉ុនប៉ងមុតមាំ អាចធ្វើកើត

« អ្នកមានបំណង ចិត្តតាំងដម្រង់ ផ្ទង់ធ្វើការអ្វី តែងបានសម្រេច កិច្ចនាលោកិយ ទោះបរលោកក្តី សឹងបានជួបប៉ង » ។

8 — Lion rampant n'est pas soumis —
សិង្ហក្រាបល្បួន មិនមែនចុះចាញ់

« កុំឃើញខ្លាក្រាបថាខ្លាសំពះ កុំឃើញដំបៅស្រះលែងដឹកថ្នាំ ឯសិង្ហល្បួនក្រាបត្រូវយើងចំណាំ កុំលោរលាំនាំបង់ប្រាណ » ។

9 — Tout ou rien —
៩ - ទាំងអស់ឬសោះទេ

« បើបានជាយកៗ ចាំនឹកសំ ឬសោះទទេល្អជាជាង បើច្រើនឲ្យ ឃាតខែតដើមជាង បើនឹងរកជានិយល់ចរិយា ។

10 — Plus d,honneur que d'honneurs —

១០ - មានកិត្តិយសចំពោះខ្លួន ជាជាងកិត្តិយសដែលគេឲ្យ

«ប្រព្រឹត្តសោភ័ណ កេរ្តិ៍ឈ្មោះគ្រប់គ្រាន់ កិត្តិយសថ្លៃថ្លា ប្រសើរជាជាង បដិសណ្ឋារ ជួបលៀងអាហារ គ្រាន់ជាកិត្តិយស » ។

11 — Etre et non paraître —

១១ - ត្រូវនៅឲ្យទៀង កុំធ្វើបន្ទំ

« ជាងទងធ្វើភាពជាះចៅក្រម ជនពាលបន្ទំជាបណ្ឌិត ខ្លួនជាអ្នក ថ្លៃពីហាងក្រិត ប្រាជ្ញស្គាល់ចរិតឥតគន្ធា » ។

12 — Mon âme à Dieu, ma vie au roi —

១២ - ព្រលឹងខ្ញុំនៅនឹងព្រះ ជីវិតខ្ញុំនៅនឹងស្ដេច

« ព្រលឹងខ្ញុំបូជាព្រះមានបុណ្យ មានព្រះទ័យករុណាគុណអនេក ឯមហាក្សត្រជាបង្អែក ទន់គុណអគ័រគលើជីវិតខ្ញុំ » ។

13 — Fais ce que dois, advienne que pourra —

១៣ - ត្រូវធ្វើការដែលត្រូវធ្វើ តាមយថាកម្ម

« បំពេញកិច្ចខ្លួន ការជំទាំមុន ឬតាមធម្មតា ត្រូវតែប្រឹងធ្វើ អំពើ នោះណា ទុកស្រាលម្តេចម្តា ស្រេចយថាកម្ម » ។

14 — Tél fiart ( frappe ) qui ne tue pas —

១៤ - សម្លាប់ មិនស្លាប់

«រូបសម្លាប់បាន ត្រង់ចិត្តក្លាហាន មិនអាចមរណា ត្រូវហាត់ចិត្ត
គាប់ សម្លាប់ក្លៀវក្លា ទើបជាតិសាសនា ថ្កុំថ្កើនរុងរឿង » ។

15 — Poing gênant, point gêné —

១៥ · គេឲ្យទុក្ខយើង ។ ឲ្យទុក្ខគេ

«បើគេធ្វើបាបយើង ត្រូវតែតប តាមរបបបែបច្បាប់ក្នុងលោកិយ
ហាមមិនឲ្យប្រទុស្តទាំងប្រុសស្រី ដើម្បីសេចក្តីសុខទាំងអស់គ្នា » ។

16 — Blessure au cœur, jamais à l'honneur —

១៦ សូវឲ្យមានរបួសដល់ចិត្តចុះ កុំឲ្យតែមានរបួសដល់កិត្តិយស

«របួសចិត្តនេះមើលមិនយល់ ដល់កិត្តិយសល្អប្រិមប្រិយ អ្នកផង
សរសើរនាលោកិយ ដោយក្តីចប់ការសុចរិយា ។

17. Qui désire n'a repos

១៧- អ្នកណាចង់ នៅមិនស្រណុក

«ចង់មានចង់បាន ចង់សុខ ក្សេមក្សាន្ត ចង់មិនរេះរប់ តែចង់ឲ្យមា
ចំរើនលាភយស ចង់ចំរើនសព្វ ឥតមានព្រំដែន » ។

(មានត)

# រៀនធ្វើស្រែខ្មែរ កម្ពុជាក្រោម

កូស័ងស៊ុន

## លោកអាចារ្យ ឌិញ - ប្រាជ្ញ រៀបរៀង

(តទៅ)

---

ម្យ៉ាងទៀត បើស្រែកនោះមានទឹកហៀរចៀនដល់ស្រូវពូជដែលស្រង់ហើយផ្អាប់ទុកនោះ ត្រូវ ១ ថ្ងៃជន់ទឹកស្រោចលានម្ដងៗ ហើយត្រូវផ្អាប់ទុកទៅវិញ ធ្វើយ៉ាងនេះទើបពូជនោះដុះបានល្អ បើមិនធ្វើដូច្នេះពូជនោះដុះមិនបានល្អទេ នេះនិយាយតាមរបៀបពីដើម តាមរបៀបថ្មីយកពូជទៅច្រកក្នុងការុងចងមាត់ឲ្យជាប់យកទៅត្រាំក្នុងទឹកចំនួន ៦ យប់ ហើយស្រង់ទុកលើគោកចំនួន ១ យប់ ឬ ២ យប់ស្រាប់តែយកទៅសាបតែម្ដងក៏បានដែរ ។

## អំពីការសាប

ទីដែលមិនភ្ជាប់ទឹកនឹងទីដែលបាចទឹក របៀបសាបដូចគ្នាគឺដែរ សាបតាមចង្អូរដែលដើរកាត់ទីនទីនោះម្ដង ៦ ចង្អូរ ។ រហូតដល់ពេញទី គឺយកស្រូវពូជមកដាក់ក្នុងកញ្ឆេយកទៅបាចម្ដង ១ ដៃ ។ ឲ្យស្មើ ទីដែលបាចទឹករងាយសាបទេ ព្រោះមើលឃើញគ្រាប់ស្រូវដែងថាក្រាស ស្តើង ទីដែលមិនបាច់បាចទឹកពិបាកបំណាល់ចន្លោះ ព្រោះមើលមិនឃើញ

មិនដឹងជាក្រាស់ស្តើង ហេតុហ្នឹងត្រូវយើងចំណាំថាកន្ទ្រងណាបាន បាចគ្រាប់ស្រូវទៅហើយ កន្ទ្រងណាមិនទាន់បាច បើមិនពិនិត្យឲ្យម៉ត់ចត់ទេ ជួនកាលបាចពានពាទៅលើកន្ទ្រងដែលសាបហើយ ម្ល៉ោះហើយដល់សំណាបនោះដុះឡើងមានក្រាស់ដើមសំណាបពុំសូវល្អ ។

សំណាបដែលទើបសាបដុះពន្លកឡើងស្រួច ១ ហៅថា ដញ្ញត្រី ដល់ដុះវែងឡើងបន្តិចទៀតហៅថាបន្លាស្រូវ ដល់បែកមានសន្លឹកពីរ ហៅថាចំពាមថ្មោល ។

ទីដែលភ្ជួបទឹកសាបបាន ៤ - ៦ ថ្ងៃត្រូវបញ្ចូលទឹកមកវិញកុំទុកយូរពេកក្រែងដីក្រៀមស្ងួតស្រែដុះព្រៃច ការបញ្ចូលទឹកបញ្ចូលឲ្យតែល្មមកុំឲ្យលិចកុនសំណាបខ្លាចក្រែងថ្ងៃក្ដៅខ្លាំង ក្ដៅទឹកពេករលួយសំណាបអស់ ។

វិធីស្ទាបពូជឲ្យត្រូវនឹងដីកុំឲ្យខ្វះលើស បើទីទំហំ ១ កុងដីត្រូវត្រាំពូជចំនួន ៣ ថាំង បើទីនោះធំជាងនោះទៅ ត្រូវត្រាំពូជឲ្យកើនតាមចំនួននោះទៅ ។

វិធីស្ទាបពូជឲ្យត្រូវនឹងដីស្រែវិញ បើធ្វើស្រែ ៤០ កុងត្រូវសាបពូជចំនួន ៧ ថាំង ១ ចំពោះ (តៅ) បើធ្វើតិចឬច្រើនជាងនោះត្រូវបន្ថែមឬបន្ថយពូជតាមចំនួននោះទៅ ។ ម្យ៉ាងទៀត បើស្រុកនោះដីមានជាតិល្អ

ត្រូវបន្ថយពូជឲ្យតិចចុះមកវិញ បើដីមិនសូវមានជីជាតិល្អទេ ត្រូវបន្ថែមពូជខ្លះទៀតក៏គួរដែរ ។

កាលបើបានសាបហើយ ត្រូវរៀបចំដីស្រែដោយស្រួលកន់ គឺពេលព្រឹកព្រលប់ ពេលថ្ងៃត្រូវទប់ភ្លឺ ទំនប់បង្ហាំងទឹកទុកឲ្យជាប់ ដើម្បីឲ្យរលួយស្មៅនិងឲ្យរលាយអាចម៍ដីណាស់ ឆាយទឹកស ត្រូវកស់ឲ្យបែកដីស្ពុ អ្នកខ្លះគ្រាន់តែភ្ជួរកស់ហើយប៉ុណ្ណោះ ហើយបើមានស្មៅដុះឡើងចន្លួចចន្លួ គេយកផារទៅត្រាយហើយស្ទូងតែម្តង អ្នកខ្លះភ្ជួរកស់ហើយថែមកាប់ដុកទៀត ប្រយោជន៍ឲ្យបែកដីហើយឲ្យកប់ស្មៅល្អផង ហើយបើនៅមានស្មៅដុះឡើងខ្លះទៀត ត្រូវត្រាយចេញឲ្យអស់ហើយទើបស្ទូង នេះរបៀបធ្វើដីដោយកំឡាំងក្របីគោ ។

របៀបធ្វើដោយកំឡាំងមនុស្សវិញនោះ គឺគេយកផារទៅកាប់ដៃម្នាក់កាន់ទំពក់ក្លាស្មៅ ដែលបាចហើយឲ្យស្រឡះពីមុខផារហើយនឹងកាប់តទៅទៀត កាប់ថែបៈនះតាល់តែហើយស្រែ ស្រុកខ្លះគេនិយមភ្ជួរស្មៅធ្វើជាជួរៗហៅថាពូន ស្រុកខ្លះគេគុតនៅដដែល គ្រាន់តែដើរត្រួសត្រាយស្មៅដែលកាប់ហើយ សាដុះឡើងវិញបន្តិចបន្តួចហើយស្ទូងទៅ កាលបើធ្វើដីស្រែស្ពុតគ្រប់ត្រជាក់ ថ្ងៃផលស័ណ្ឋាប ។

# អំពីរបៀបដកសំណាប

បើដីស្រែមានជីជាតិល្អ ត្រូវទុកសំណាបឲ្យបានតែ១ខែចាំដក កុំទុកឲ្យសំណាបចាស់បន្តិច ព្រោះដីស្រែនៅក្តាំងបើស្ទូងសំណាបខ្ចី បែកគុម្ពធំស្លឹក សាកតោក ស្រូវមិនសូវបានល្អទេ បើស្រែនោះហាល មិនសូវមានជីជាតិ ទុកសំណាបចំនួន ៤៥ ថ្ងៃ ឬ ៥០ ថ្ងៃ ត្រូវដកហើយ ព្រោះដីខ្សោយកុំទុកឲ្យទល់តែខែ សំណាបចាស់ពេកស្ទូងមិនសូវបែកគុម្ពទេ ហេតុហ្នឹងមុននឹងដក ត្រូវពិនិត្យមើលដល់ដីស្រែផង តើត្រូវដកសំណាបខ្ចី ឬត្រូវទុកសំណាបឲ្យចាស់ ឯរបៀបដកសំណាបនោះយ៉ាងនេះគឺ យកម្រាំងទៅដោតចំនួន ១ ចំអាមពីរ ហើយរបៀបដកនោះត្រូវមានកំណត់ដូច្នេះគឺ ស្ទា (ចាប់) ដកម្ដងបួនដើមបើសំណាបនោះដោយដីរឹងត្រូវរាយ គោះទឹកកែងជើងម្ដងបួនដើម ហើយដកតទៅទៀតឲ្យពេញណេនដៃម្ខាងទេនដាក់ចុះម្ដង ហើយចាប់ដកតទៅទៀតឲ្យបានពេញដៃ ហើយយកទៅប្រមូលនឹងដៃដកមុននោះ ហើយចាប់ក្របួចពុនឲ្យជាប់ គក្រោមទៅក្នុងទឹកឲ្យជ្រះដីឲ្យអស់ ហើយត្រូវខ្ទប់គ្រោបសំណាបពីខាងគល់ឲ្យជាប់ ក្រឡាស់ស្ទុកសំណាបដែលដកជាប់នោះចេញឲ្យអស់ ហើយជំឲ្យស្មើ ហើយយកទៅដាក់គនឹងលើព្រាំងម្ដង ហើយចាប់តាំងដកតទៅទៀត បានពេញពីរដៃក៏ឈានជំយកទៅដាក់លើព្រាំងដូចពេលមុនទៀត គប់ ៣ ដងចងម្ដង និយមចំណងចងឲ្យតៀត

ទឹកក្រៅថ្នាលក៏ចូលពីផ្ទៃទៅដាច់ហើយ បើសំណាបនោះវែង កាត់ចុងចោលខ្លះក៏បាន បើសំណាបនោះខ្លីមិនបាច់កាត់ចុងចោលទេ គ្រាន់តែចងហើយដាក់ចុះពីថ្នាលទៅហើយដកតទៅទៀត លុះកាលណាត្រូវការគ្រប់ចំនួនដែលត្រូវការ ៗ របៀបដកនេះ ពីរដៃដក ត្រូវជា ១ ដៃធំ បីដៃធំបីដៃដកត្រូវជា ១ កណ្តាប់ របៀបដកទីនដើមវាក៏ដូចដកខ្ទិះថ្នាលដែរ ខុសគ្នាតែមួយដកដាក់លើថ្នាល មួយដកដាក់លើដើមវា ប៉ុន្តែដកទីនដើមវាឆាយជាងដកថ្នាល ព្រោះបានដើមវាធ្វើជាក្តារធំតែម្តង ៗ

សំណាបដែលដករបៀបនេះ ១ ចូនស្ទូងបាន ២ កុង បើធ្វើបានចំនួនប៉ុន្មាន ក៏ដកសំណាបឱ្យត្រូវតាមរបៀបដែលកំណត់ឱ្យប៉ុណ្ណោះ សំណាបដែលដកហើយផ្អាប់ទុកបាន ១ យប់ ២ យប់ត្រូវស្ទូងឱ្យអស់ បើស្ទូងមិនទាន់សោះត្រូវផ្អាប់ទុកបាន ៣ យប់ជាយ៉ាងយូរ បើហួសកំណត់នេះទៅត្រូវស្រាយចំណងចេញឱ្យហើយដើមសំណាប បើទុកចាំនឹងចំណងមិនស្រាយ ក្តៅគគរលួយដើមសំណាបអស់ ៗ

## អំពីរបៀបស្ទូង

ដីដែលបានធ្វើស្រែត្រៀមហើយ ត្រូវរាស់ឱ្យដឹងចំនួនថាបានប៉ុន្មានកុង ហើយដកសំណាបឱ្យត្រៀមតាមចំនួននោះទៅ យ៉ាងហោច ១ កុងឱ្យបាន ២០ កណ្តាប់ បើតិចជាងនេះខាតមិនពេញកុង ៗ ឯរបៀបស្ទូងនោះមាន

២ បែប ១ បែបស្ទូងដៃ គឺគេយកកណ្ដាប់សំណាប ហើយចំនួន ៣ គាប រំលែកយក ១ គាប់មកត្រកងលើដៃម្ខាង ដៃម្ខាងបេះសំណាបស្ទូងទៅក្នុងស្រែ តែស្ទូងបែបនេះចំពោះតែស្រែណាដែលដីទន់ បើដីរឹងស្ទូងមិនបានទេ ។ ១ បែបទៀតស្ទូងឈើច្រាន គឺគេយកកណ្ដាប់ហើយបំបែកសំណាបចំនួន ១ ចំហៀងកណ្ដាប់យកទៅបេះដាក់ ១ ដៃៗ ហែទៅមុខ ហើយវិលទៅយកឈើច្រានមកកាន់ដៃម្ខាង ហើយយកសំណាបដែលបេះដាក់មុខនោះ ១ ដៃមកកាន់ផ្ទាប់ទីងឈើច្រាន ហើយលើកឈើច្រានចុកទៅក្នុងដីឲ្យមានប្រហោង ហើយដៃ ១ ដែលចាំនៅក៏បេះសំណាបដែលកាន់ភ្ជាប់ទីងឈើច្រាននោះស្ទូងតាមប្រហោងឈើច្រានទៅ ។ បើស្រែហាលមិនសូវមានជី ត្រូវស្ទូងចំនួន ១ ហ្គុ ១ គុម្ព បើស្រែនោះដីមានជីជាតិច្រើនត្រូវស្ទូងឲ្យរង្វើលជាងនោះ កុំញឹក ស្រូវបែកគុម្ពលោយចូលគ្នាស៊ីកម្រោមកោកម៉ោក គួរស្រូវមិនសូវបានពេញគ្រាប់ល្អ សន្ទូងដែលស្ទូងហើយនោះជួនណាមានខូចខាតដោយទឹកលិចឬក្ដាមគេកាត់ក៏ដោយ ត្រូវជួសជុលធ្វើឡើងវិញកុំទុកឲ្យបង់ត្រណោត ។

## អំពីការជួស

ការជួសនោះមាន ៣ បែបគឺ

១ — ជួសដោយសំណាប គឺដកសំណាបយកទៅស្ទូងជួសកន្លែងដែលខូចនោះ ។

២ ស្ទូងដោយសា គឺយកសំណាបដែលដកដាច់ហើយសាដុះឡើងវិញ ត្រូវដកយកសានោះឯងទៅជួសកន្លែងដែលចង់ត្រូវការនោះ ។

៣- ស្ទូងដោយសន្ទូង គឺសន្ទូងដែលស្ទូងយូរហើយ ៗ បែកគុម្ព ត្រូវយកកាំបិតទៅកាត់គុម្ពសន្ទូងនោះឯងកាត់ឫសចុកឱ្យទៅខ្លី ហើយយកគុម្ពសន្ទូងនោះទៅ បំបែក ១ គុម្ពបែកបាន ៤-៥ គុម្ពទៅ តែការស្ទូងដោយសំណាបនោះបានតែសំណាបដែលខូចដោយទឹកលិចឬត្រូវក្តៅពេកស្លាប់ នោះទើបស្ទូងដោយសំណាបបាន បើខូចដោយក្តាមកាត់ដង យកសំណាបទៅស្ទូង ក្តាមក៏វាតែកាត់ដែរទៀត ព្រោះសំណាបដើមតូចងាយកាត់ បើខូចដោយក្តាមកាត់ត្រូវស្ទូងដោយសាឬសន្ទូង ព្រោះសានិងសន្ទូងដើមវាធំក្តាមកាត់មិនសូវបាន ប៉ុន្តែបើមានសាគ្រប់គ្រាន់មិនត្រូវយកគុម្ពសន្ទូងទេ ព្រោះសាបាចបែកគុម្ពជាងសន្ទូងផង ទាំងមិនបាច់កាត់គុម្ពសន្ទូងដែលស្ទូងហើយនោះផង តែបើគ្មានសាគ្មានសន្ទូងគុម្ពធំទេ ទុកជាសំណាបក៏ត្រូវស្ទូងដែរ បើក្តាមវាកាត់ក៏គង់មានសល់ទៅខ្លះមិនទេឡើយ ។

កាលស្ទូងទៅ ត្រូវមើលដីកុំទំនប់ បើជ្រៅពេកត្រូវបង្ហូរចេញខ្លះទុកឲ្យតែល្មម តែទុកជ្រៅពេកជាហេតុធ្វើឲ្យស្រូវស្រយ បើទឹកតិចត្រូវរកទឹកទុកប្រយ័ត្នកុំឲ្យគោកក្រៀមខ្លាចក្រិនស្អក បើស្រូវនោះចេញ

ដាក់ទឹកដោះ[១] ឬណាមួយទុំផុតថ្ងៃដែលៗហើយ បើស្រូវនោះគោក គេមិនត្រូវរំពឹងតែល្អថែមទៀត គឺនាំឲ្យផលការច្រូតកាត់ផង ទាំងមិន លំបាកល្អដល់គ្រាប់ស្រូវដែលទុំនោះផង ហើយបើស្រូវក្រហមៗនេះ ត្រូវដើរមើលឲ្យរៀបរយបន្តិច បើឃើញថាទុំសព្វហើយកុំទុកឲ្យទុំញួស ដល់ទៅធ្លាក់កួរស្អិតទង ពេលច្រូតល្អតជ្រុះគ្រាប់ស្រូវច្រើនណាស់ នោះនាំឲ្យបង់ខាតផលកំរៃ ។

## របៀបច្រូត

ការច្រូតនេះ គេយកកណ្ដៀវទៅកាត់ក្ដុំស្រូវម្ដង ១ ក្ដុំឬ ២ ក្ដុំ តាមស្ទាត់មិនស្ទាត់ ហើយកាត់ពាក់កណ្ដាលឬជាទាក់កណ្ដាលដើមស្រូវ តាមស្រូវវែងខ្លី បើស្រូវខ្លីកាត់ពាក់កណ្ដាលដើម បើស្រូវវែងកាត់ទៀតទៅចុងបន្តិច កុំកាត់វែងពេកពិបាកបោកណាស់ កណ្ដាប់ស្រូវនោះទៀត ស្រុកខ្លះច្រកពេញពីរដៃចងម្ដង ស្រុកខ្លះចាប់បួនដៃចងម្ដង កណ្ដាប់ដែលចងពីបួនដៃចងម្ដងនោះបោកមិនស្រួលជ្រះទេ ។ គេច្រើនច្រកបាច់គោ បញ្ឈរ រៀបបញ្ឈរទន់មានអធិប្បាយកទៅខាងមុខ ។

បើស្រូវនោះគោក ច្រូតហើយត្រូវសាប់ឲ្យក្រៀងក្ដាប់ដីពេលហើយ ដាក់កណ្ដាប់នោះទៅ បើស្រូវនោះទឹក ត្រូវធ្វើជើងក្អក គឺយកឈើក្រៀង

---

១ គឺក្នុងគ្រាប់ស្រូវនោះមានទឹកសៗដូចទឹកដោះ ហៅថាដាក់ទឹកដោះ ។

១ ក្តួច ចងបត់ជាពីរជាគប់កណ្ដាល ហើយបង្អោនកញ្ច្រាំងជុំវិញ នោះឥឡូវពីលើ ហើយដាក់កណ្ដាប់សន្ទក់កញ្ច្រាំងនោះទៅ ធ្វើដើមកុតនេះ ឥតឆ្អារគុំឲ្យទទឹមស្រុះ បើប្រគេហើយសព្វគ្រប់ត្រូវប្រមូលកណ្ដាប់ធ្វើជា ពន្លូតហៅថាពូក ។

ពូកកណ្ដាប់នោះមានពីរបែប ១ បែបពូកវែង គឺបើស្រែនោះគោកគេ ត្រាន់តែកាត់កញ្ច្រាំងត្រាប់ពីក្រោមឲ្យវែងចំនួនចុះកណ្ដាប់បាន ៤ ដប់ ហើយផ្ទួនកណ្ដាប់មករៀបវែងឲ្យគប់ ៤ ដប់ ហើយក្រោយរៀបតរៀត ឡើងម្ដង ១ ស្មើ ៗ ដាល់គប់ ១០០ កណ្ដាប់ធ្វើជា ១ ពូក ហើយបើរៀប ក្បាលកណ្ដាប់ទៅខាងណា ក៏រៀបទៅខាងណោះទាំងអស់ នេះហៅពូក វែងឬពូក ១ ចំហៀងស្ដាក់ក៏បាន ។ បើស្រែនោះនៅឆាកទឹកត្រូវលើកដី បន្តិច ហើយសឹមកាត់កញ្ច្រាំងត្រាប់ខ្លះ បើមិនលើកដីសោះខ្លាចសើម ដល់កណ្ដាប់ ។

១ បែបទៀតពូក ៤ ជ្រុង ពូកនេះធ្វើទទាប់ក្រោមដូចពូកមុន ដែរ ប៉ុន្តែពូកមុនវែង ពូកនេះរៀប ៤ ជ្រុង គឺរៀបបុនបូលទល់គ្នា យកក្បាលកណ្ដាប់ចេញទាំង ៤ ខាង រៀបយ៉ាងនេះដាល់គប់ ២ ឬ ៤ ដប់ សល់ ១ ដប់ដាក់ឲ្យចំពីលើនិការពារកុំឲ្យភ្លៀងហូរចូលចំកណ្ដាល ពូកបាន ។ (មានត)

# អ្នកឧកញ្ញាវិបុលរាជសេនា នូ-កន់

## ដំណាងក្រស្ដ

(តទៅ)

ខ្នងសេះ ហើយចូលទៅក្រាបថ្វាយបង្គំព្រះរាជកុមារនាំងពីរព្រះអង្គ ដែលគង់លើព្រះរាជរថនោះ ចាងជូហៀបមានព្រះបន្ទូលថា អ្នកនេះជាមនុស្សស្គាល់ខុសត្រូវចេះនិយាយពាក្យដើមពាក្យចុងត្រូវគ្នា មិនបង់ប្រយោជន៍ដែលទ្រង់ចិញ្ចឹមឱ្យធ្វើជានាហ្មឺនធំតទៅទៀត ។ នាំងគុះបានឮដូច្នោះក៏ទ្រង់គិតតែក្នុងចិត្តថា ចាងជូហៀបមានព្រះសតិបញ្ញាឆ្លៀវឆ្លាតជឿនជឿនបាន ដែលទ្រង់មានបន្ទូលក៏ស្រួលពិរោះមិនខាសត្រង់ណា អញនឹងគិតដោយប្រាជ្ញាខ្មាក់ចាងជូហៀនចេញ ហើយនឹងលើកយកចាង-ជូហៀបឱ្យសោយរាជសម្បត្តិវិញឱ្យបាន នាំងគុះគិតដូច្នោះហើយក៏ថ្វាយបង្គំនាំពលទាហានថយទៅតាំងទ័ពនៅខាងក្រៅកំពែងព្រះនគរ ។

ខណៈនោះព្រះនាងហ៊ូហៅបានឃើញព្រះរាជបុត្រត្រឡប់មកវិញ ក៏មានសេចក្ដីសោមនស្សណាស់ ព្រះនាងបានត្រួតពិនិត្យមើលបណ្ដាព្រះរាជទ្រព្យដែលមានក្នុងថ្លៃព្រះឃ្លាំង ក៏សឹងតែសម្បូណ៌នៅដូចដែល បាត់តែត្រាព្រះសង្ហាដែលសម្រាប់ប្ដឹកដការក្នុងព្រះនគរ ។

គ្រានោះ តាំងគុះដ៏មានសទ្ធាចិត្តក្រៀមក្រំ រមែងលើកពលសេនាចូលមកលេងក្នុងព្រះនគរជារឿយ ៗ បណ្ដាពួកពលទាំងពួងក៏សុទ្ធតែមកដណ្ដើមយករបស់ទ្រព្យ ទំនិញចំណីអាហាររបស់អាណាប្រជានុរាស្ត្រទាំង-ឡាយជាជ្រួលច្របល់ក្រៃ មនុស្សក្នុងព្រះនគរក៏មិនមានអ្នកណាតវ៉ាថាម្ដេច ឯតាំងគុះនោះបើនឹងចូលទៅក្រាបបង្គំគាល់ ក៏ធ្វើមិនស្គាល់អស់សេនាបតីធំៗ មិនមានសេចក្ដីគួរសមទំលាប់តាមធម្មតា ។ ចៅស៊ុនបានឃើញវេលាណា ក៏ប្រឹក្សានឹងអ្នកស្រីថា តាំងគុះនេះអំណួតយូរទៅគង់នឹងគំរើបចិត្តគិតធ្វើការគេក្រក់មិនខាន យើងត្រូវតែគិតអានបំផ្លាញវាលានវាចេញជាមុន ។ អ្នកស្រីឆ្លើយថា វេលានេះដែនដីទើបតែនឹងស្ងប់ បើយើងនឹងត្រឡប់គំរើតទៀតនៅក្នុងមិនស្រួល ។ ចៅស៊ុនឃើញថាអ្នកស្រីមិនព្រមចូលនិងគិតជាមួយនឹងគ្នា ក៏ម្មាទៅរកអង់ស៊ុនហើយប្រឹក្សាជួបនិយាយនឹងអ្នកស្រីនោះ អង់ស៊ុនត្រូវចិត្តជួបគំនិតរបស់ខ្លួនក៏សុំឲ្យបង្អង់នឹងបយទៅត្រិះរិះរេចបាយ ចៅស៊ុនមិនសប្បាយដោយចិត្តព្រោះ ក៏កើតទោមនស្សតែម្នាក់ឯង ទើបនាំបក្ខពួកចេញទៅនៅក្នុងព្រៃ ។

ឯតាំងគុះតែងតែបញ្ចុះបញ្ចូលសេនាទាហានដែលធ្លាប់នៅតាមស្រុយនឹងហ្វូងចិនពីមុននោះ ស៊ីងចុះចូលទៅនៅខាងខ្លួនទាំងអស់ តាំងគុះក៏កាន់តែគំរើបចិត្តគិតខឹងលើយូរថា យើងបង់នឹងទម្លាក់ហង់ដូពៀនចេញបានរាជសម្បត្តិ ហើយលើកហង់ដូហៀនឲ្យសោយរាជ្យជាថ្មី រាជការ

ផែនដីក៏គង់នឹងជាប់ស្រេចនៅលើយើង អំណោះទៅមុខបើយើងនឹង
ប្រាថ្នាយ៉ាងណា ក៏គង់នឹងបានសម្រេចស្រួលដោយងាយ ។ លឺយូរ
គេថា សព្វថ្ងៃនេះមានស្តេចក៏ដូចជាមិនមានស្តេចសោះ សេនាបតីទាំង
អស់ក៏សម្រេចកិច្ចការពុំបាន ដែលមានប្រសាសន៍គតកានដូច្នោះគួរ
ណាស់ ព្រោះសម័យនេះផែនដីកំពុងនឹងស្ងប់ជាសុខក្សេមក្សាន្ត សូម
តិតកានជាប្រញាប់ចុះ ។ ប្រការមួយទៀត សូមឲ្យលោកប្រមូលអស់
បណ្ដានាហ្មឺនមុខមន្ត្រីតូចធំទៅជួបជុំនៅទីសួនផ្កា គំបន់អ៊ុំនបេងហ៊ុយ បើ
ប្រជុំព្រមហើយឲ្យប្រកាសថា ត្រូវម្នាក់ហានដូចពៀនចេញតាកកជសម្បត្តិ
ហើយលើកហានដូចហៀបឲ្យសោយរាជ្យវិញ ៖បើនាហ្មឺនណាមិនយល់
ព្រមឲ្យចោមចាប់កាប់សម្លាប់ចេញមួយរំពេចឲ្យបាន លោកក៏នឹងមាន
កាថាស្ទើផាច់នាគគទៅ ។

កាំងគុះបានស្ដាប់ក៏មានចិត្តសោមនស្សត្រេកអរ មានវាចាថា ពាក្យ
ដែលអ្នកនិយាយនោះត្រូវណាស់ លុះគន្ទងមកថ្ងៃមួយនោះ កាំងគុះឲ្យរៀប
កាហារភោជន ហើយឲ្យអញ្ជើញនាហ្មឺនមុខមន្ត្រីតូចធំទៅជួបជុំបរិភោគ
នាហ្មឺនតូចធំសិងនិយមគោរពក្នុងអំណាចកាំងគុះទាំងអស់គ្នា វេលាដែល
បានទៅជួបជុំក៏នាំគ្នាទៅបរិភោគក្នុងសួនផ្កា លុះអគ្គិយចុះព្រមគ្នាហើយ
កាំងគុះក៏ឈានទ្រកែបរចេញមកឈរកណ្ដាលគុ ហើយប្រកាសថា អស់លោក

ទាំងអស់គ្នាកុំគាលសេពសុក ខ្ញុំនឹងសុំនិយាយការពជការខម្ពបេសន៍ នាហ្មឺនទាំងអស់ក៏សម្ងំចាំស្ដាប់ ។

ទើបតាំងគុះនិយាយថា សព្វថ្ងៃនេះហានដូពៀនបានទទួលគ្រងរាជ-សម្បត្តិ ឧបមាបីដូចជាសិរីសោភ័ណហ្ម័យនៃអគ្គមហាសេនាបតីនាហ្មឺនសព្វមុខមន្ត្រីនូវអស់អាណាប្រជានុរាស្ត្រទាំងពួង តែថាក្សត្រនេះមិនមានបុណ្យានុភាពអាចនឹងកំរាបបច្ចាមិត្របាន ព្រោះគ្មានតបះតេជះឲ្យជាទីគោរពខ្លាច ។

ឥឡូវខ្ញុំឃើញហានដូហៀបជាព្រះអនុជ មានសតិបញ្ញាក៏វៃជាងចេះរក់ហារក្លាហាន ខ្ញុំនឹងផ្ដួលហានដូពៀនចេញពេលនេះ ហើយលើកហានដូហៀបឡើងឲ្យសោយរាជសម្បត្តិវិញ ទើបផែនដីនឹងបានសេចក្ដីសុខសប្បាយ អ្នកទាំងឡាយនឹងយល់ឃើញប្រការដូចម្ដេច ។

បណ្ដានាហ្មឺនតូចធំក៏សម្ងំនៅស្ងៀមទាំងអស់គ្នា តែតេងង៉ួនជាចៅ-ហ្វាយស្រុក តេងជីវ ឮដូច្នោះក៏ស្ទុះក្រោកឡើងឈរហើយនិយាយថា ខ្លួនអ្នកឯងគ្រាន់តែជាទីកំណែនមន្ត្រីនៃក្រៅ មិនត្រូវមានអំណាចនឹងផ្ដួលម្ចាស់ផែនដីឡើយ ព្រោះហានដូពៀនក៏ជាព្រះរាជឱរសច្បង គួរនឹងគ្រងរាជសម្បត្តិ ជំនួសព្រះបិតាទៀតផង តាមព្រះរាជប្រវេណីអំពីបុរាណ ព្រះអង្គក៏នឹងមានសេចក្ដីខុសត្រង់ណា ដែលអ្នកឯងមានកាចដូច្នេះនឹងបង់ជាសត្រូវកែផែនដីអ្វី ? ។

តាំងតុះបានស្ដាប់ដូច្នោះទើងណាស់ ក៏ស្រែកហៅថា យើងប្រឹក្សាជាការល្អណាស់ ចុះហេតុម្ដេចខ្លួនក្រឡាសធ្វើយចចិនឹងពាក្យរបស់យើងដូច្នេះ យើងត្រូវតែកក្បាលទីងក្របនេះឥឡូវ ថាហើយក៏ហូតស្រោមក្របចេញ គិតនឹងដេញឈប់តេងខ្លួន ។

លីយូក្រទៀតឃើញលីប៉ោឈរតែក្រោយ តេងខ្លួនមានខ្លួនធំខ្ពស់កាន់លំពែងនៅដៃយ៉ាងគង់កាច ក៏ចិកបារម្ភខ្លាចទើបចូលទៅសុំជំរាបយាត់តាំងតុះថាថ្ងៃនេះ យើងអញ្ជើញអស់លោកមកជួបជុំពិសាក្រយា-ហារ នូវតែចឹងស្ដាប់ចម្រៀងរបាំកំលេងសប្បាយ ម្ដេចមកនិយាយប្រកួតប្រកែកជាដែកគ្នា ទៅមានវេលាតែថ្ងៃមួយនេះទេឬ ? គង់មានថ្ងៃតទៅទៀតនឹងប្រឹក្សាគ្នាបាន ឬទើងចង់តក់ផលសាលាលួចយុទ្ធចុះថ្ងៃនេះអញ្ជើញពិសាឲ្យសប្បាយ ។

បណ្ដានាហ្មឺនទាំងឡាយ ក៏ហាមឃាត់តេងខ្លួន ក៏ឡើងសេះនាំលីប៉ោវិលទៅវិញ ឯតាំងតុះក៏ពិគ្រោះនឹងនាហ្មឺនទាំងអស់ថា យើងប្រឹក្សាអម្បាញ់មិញនេះអស់លោកនឹងយល់ឃើញយ៉ាងណា ជាត្រូវឬខុស លោទំតគបថា លោកប្រឹក្សាការពជការនោះខុសណាស់ ព្រោះព្រះហៅឡេនគេជាព្រះវរពជបិតាទ្រង់ត្រាថថា ហាងដូចៀនជាព្រះពជបុត្រច្បងមានសតិបញ្ញា គួរនឹងឲ្យឡើងសោយរាជសម្បត្តិបាន ខ្ញុំលោកត្រឹមតែជាមន្ត្រីទៃត្រក្រៅនៅមិនទាន់គួរប្រាស់ ព្រះរាជបញ្ញត្តិច្បាប់តាម

សណ្ដាប់ចាកប្រណី  ទើបមកដកហូត  ហាក់ដូចទៀនដែលមិនមាន
ប្រេងក្ដៅសនោះមិនគួរ  តាំងតុះព្រួញពោះក៏រកតែទីណាស់
ហូតក្រេបប្រេងកាច់លោហិតនៅទីនោះ  ដៃចុះក៏ស្ទុះទៅហាមឃាត់ថា
លោហិតនេះជាមន្ទិលមកពីដើម  សន្ដានចិត្តក៏ស្រុបរំភើបទៀត ត្រង់ទីនេះកផការ
បណ្ដាតាហ៊ីនមុខមន្ត្រីតូចធំទាំងពួកការខុសណា ប្រជានុក្រ្តតាំងឲ្យយ
ក៏កេះកយកបក់កាន់ស្រឡាញ់លោហិតច្រើនណាស់  បើលោកទីនេះស្លាប់
លោហិតចេញ  ប្លាស់ជាគ្រឡុះគ្រឡាប់ទាំងជីកើតភ័យអន្តរាយមិនខាន
អនីមុនក៏ធ្វើយក្ខនថាថ្ងៃនេះជាទីប្រជុំគ្នា រំភាគគាហារឲ្យសប្បាយ
បើទីនេះប្រែក្លាយកាត់កផការផែនដីក៏ត្រូវបង្អង់ដល់ថ្ងៃឯមុខចុះ  បណ្ដាតាហ៊ីន
តាំងពួនក៏គំនាប់លា តាំងតុះត្រឡប់ទៅទីលំនៅរៀងខ្លួន ។

ឯលីហ៊ោ លុះទៅដល់ទីហានជាមួយនឹងគេនឹងខ្លួនហើយ  ក៏កាន់លំពែង
ឡើងសេះរំលែ ត្រឡប់មកតាំងស្ដាប់ការកងសួនផ្កាវិញ  តាលតាហ៊ីនតាំង
អស់រលាយអស់ហើយ  តាំងតុះក៏កាន់ក្របដើរទៅដល់ទាត់ទ្វារសួនផ្កា
ក្រឡេកឃើញលីប៉ាជិះសេះចរចូលមកដល់ក្បែរចេង  ក៏សួរលីយូថា
ចាហានរបស់ខណា  លីយូធ្វើយថាលោកឲ្យមកវិញឲ្យនាំ ចាប.ន
នេះឈ្មោះលីប៉ោជាកូនចិញ្ចឹមគេនឹងខ្លួន  មានកំឡាំងខ្លាំងពូកែណាស់តាំង
តុះក៏ថយត្រឡប់មកវិញ  លុះដល់ព្រឹកឡើងមានចំរើនទៅប្រាប់តាំងតុះថា

ឥឡូវគេនឹងខ្លួនឯងលីប៉ៅយុំនាំទាហានលើកមកច្បាំងនឹងលោកហើយ តាំង-គុំនិងណាស់ក៏លេះលោះនឹងទៀតពលទាហានលើកចេញទៅ ។

ពេលនោះគេនឹងខ្លួនឯងលីប៉ៅបរសេះចេញទៅឈរមុខទាហាន ហើយស្រែកថា ត្រាមុខតាពួកខ្ញុំ ១០ នាក់បណ្ដាលហេតុជាចលាចលពេញផែនដី ទើបកើតភ័យអន្តរាយឥឡូវស្រែកទើបតែនឹងបានសុខសប្បាយបន្តិចប៉ុណ្ណោះ ខ្ញុំគ្រាន់តែជាមន្ត្រីខេត្រក្រៅមិនទាន់មានគុណបំណាច់យ៉ាងណាមកគិតតាំងខ្លួនជាធំសម្រេចការផែនដី អាចហ៊ានចេញកាត់ស្រដីថាឯងដកហូតព្រះមហាក្សត្រ ចេញអំពីរាជ-សម្បត្តិតាមចិត្តរបស់ខ្លួន ធ្វើដូច្នេះឯងឲ្យផែនដីកើតចលាចលម្ដងទៀត ដូចកាលគ្រាពួកខ្ញុំនោះឬអ្វី ។

តាំងគុំមិនទាន់តប ម៉ីដ លីប៉ៅក៏ចំផាយសេះត្រឡប់តែនឹងចូលទៅដម្រង់ទីងតាក់តាំងគុំ ១ ឃើញដូច្នោះ ក៏បរសេះស្ទុះថយទៅក្រោយ ទាហានគេនឹងខ្លួនក៏បរពលចូលទៅតក់តាប់សម្លាប់កងទាហានតាំងគុំ ១ ក៏បែកទាហានខ្ចាត់ខ្ចាយថយទៅក្រោយប្រហែល ៥០ សិន (២ គីឡូម៉ែត្រ) ទើបឲ្យតាំងបន្ទាយភាយបម្រុងជិតជាសាមភ្លោះជុំវិញជាមាំមួន ហើយក៏ប្រកាសនឹងសេនាទាហានថា តាំងពីយើងបានធ្វើសឹកសង្គ្រាមរៀងមក ក៏ជាច្រើនគ្រាហើយ មិនដែលឃើញទាហានឯណាក្លាហានខ្លាំងពូកែដូចលីប៉ៅនោះ បើប្រសិនយើងបានលីប៉ៅនោះមកជាសេនារបស់យើង

ការទាំងពួងក៏នឹងបានសម្រេចតាមប្រាថ្នា លីសុកនាយទាហានក្មេងហើយ ឆ្លើយដំណបតាំងតុថា ខ្ញុំបាទនឹងលីប៉ោនៅស្រុកជាមួយគ្នា ជាមិត្តសំ-ឡាញ់នឹងគ្នាពីតូច តែថាលីប៉ោនោះខ្លាំងពូកែមែន ប៉ុន្តែចិត្តអាក្រក់ណាស់ មិនដឹងគុណអ្នកឯណា ប្រាថ្នាតែតែទ្រព្យរបស់គាប់ចិត្ត បើលោកត្រូវការ ខ្ញុំបាទនឹងសូមទៅនិយាយបញ្ចុះបញ្ចូលលីប៉ោឲ្យបានមកនៅធ្វើការជាមួយនឹងលោក តាំងតុសួរថាអ្នកនឹងទៅបញ្ចុះបញ្ចូលដូចម្តេចទើបបានលីប៉ោមកនៅនឹងយើង ។

លីសុកឆ្លើយតបថា សូមឲ្យលោកយកទ្រព្យរបស់ដែលល្អមានថ្លៃ ហើយនឹងសេះឈ្មោះសិកតោរ (សិទ្ធរៈ) ដ៏មានកំឡាំងបរមួយថ្ងៃបានចម្ងាយផ្លូវមួយម៉ឺនសិន (៤០០គីឡូម៉ែត្រ) នោះមកឲ្យខ្ញុំបាទនាំនិងយកទៅឲ្យលីប៉ោ ហើយនឹងបញ្ចុះបញ្ចូលតាមតម្រិះប្រាជ្ញាខ្ញុំបាទឲ្យទាន់តែបានលីប៉ោចូលមកនៅនឹងលោកជាប្រាកដ តាំងតុមិនទាន់អស់ចិត្តក៏បែរទៅពិគ្រោះនឹងលីយូទៀតថា ដែលលីសុកនិយាយទាំងអម្បាលនេះតើអ្នកយល់ឃើញដូចម្តេច ។

លីយូថា ខ្ញុំបាទស៊ើបនឹងលោកណាស់ លោកប្រាថ្នាគិតការធំប៉ុណ្ណោះ ហើយមិនគួរឡើយនឹងស្តាយទ្រព្យរបស់និងសេះមួយប៉ុណ្ណោះសោះ បើសមដូចប្រាថ្នាកាលណាទ្រព្យសម្បត្តិលើសនេះក៏នឹងហូរចូលឯងមិនខាន ។

តាំងតុបានស្លាប់ផុតពោះហើយ ក៏ចុះចិត្តជឿជាក់អស់ពីពោះទើបបាត់ យកទ្រព្យរបស់គីមាសមួយពាន់ដំឡឹង ត្រូវនឹងពេជ្រដាំងគ្រាប់ ដប់កយ ក្បាលទំមខាត់ប្រដាប់ខ្សែក្រក់ ១ ហើយទឹមសេះឈ្មោះសិតលោរប្រគល់ ឲ្យលីសុខហើយផ្ដាំថា អ្នកចូរយកសេះទៅឲ្យលីប៉ោតាមគំនិតអ្នកគិតនោះចុះ លីសុកទទួលរបស់ទឹមសេះហើយ ក៏លាតាំងតុទៅកាន់ទីបន្ទាយគេនីរូខ លុះទៅដល់មាត់ទ្វារក៏ជួបប្រទះនឹងមនុស្សបំរើរបស់លីប៉ោ ចេញមកគយល្បាត ពួកនោះក៏ចាប់ខ្លួនលីសុកទុកហើយសួរថា អ្នកឯងមានការមករកអ្វីដល់ទីនេះ លីសុកឆ្លើយថា ខ្ញុំឈ្មោះលីសុកជាមិត្រសំឡាញ់នឹងលីប៉ោតាំងពីតូច ឥឡូវមានសេចក្ដីនឹករឭកលីប៉ោបានជាចូលមកនេះ អ្នកទាំង-ឡាយចូរនាំខ្ញុំទៅរកលីប៉ោចុះ ទាហានគយល្បាតក៏ឲ្យឃុំខ្លួនលីសុកទុក ហើយចូលទៅជំពបលីប៉ោ ៗ បានដឹងថាលីសុកមករកក៏មានសេចក្ដីត្រេកអរណាស់ ទើបចេញមកទទួលលីសុកនាំចូលទៅក្នុងបន្ទាយ ហើយក៏និយាយថា យើងទាំង ២ នាក់បានសំរេត្រសឡាញ់គ្នាមកតាំងពីតូច ៗ ពីជួបឃ្លាតពាក់គ្នាមកជាយូរណាស់ហើយ ឥឡូវអ្នកមកធ្វើការទៅក្នុងទីដំណែងណា លីសុកតបថា ខ្ញុំជាទីតុនឹងឡុងជៀងនាយទាហាន ដឹងជាអ្នកចូលធ្វើការជានាយទាហានជុំគ្នា បានជួយការពារដែនដីខ្ញុំក៏មានសេចក្ដីត្រេកអរណាស់ វេលានេះទឹងកេរបស់ធ្វើជាគួរសមពុំបាន មានតែសេះ ១ ឈ្មោះសិតលោរ នៅក្នុងដំណែងកំឡាំង ចរមួយថ្ងៃបាន

បម្លាយផ្លូវមុនសិន (៤០០ គីឡូម៉ែត្រ ដើម្បីនឹងព្យួរចុះថ្លែងមកគិតដូច
ជាដើរលើជើងតបតគ្នា អ្នកប្រើយកខ្លួនជាតម្រែះរបស់ខ្លួននឹងបានធ្វើការ
កដការក្រៅផែនដីទៅ លីប៉ោពុំបានស្គាប់ផ្លូវនោះ ទើបដកសេះនោះទៅ
មើលលក្ខណៈឃើញពេមនោះ ក្រហមដូចជាភ្លើងឆេះអស់ទាំងខ្លួនគ្មាន
ពណ៌ត្រង់ណាឲ្យខុសប្លែកគ្នា កំពស់ ៤ ហត្ថបាយ ត្រលក្ខណៈ
ជាសេះបង្កាំងខ្លាំងពូកែមែន លីប៉ោក៏មានសេចក្ដីសោមនស្សត្រេកអរ
ពន់ប្រមាណបានតបតទោលនិយាយថា អ្នកនាំយកសេះនេះមកឲ្យខ្ញុំ ។
អរគុណណាស់ ព្រោះសមប្រកបនឹងសេចក្ដីប្រាថ្នារបស់ខ្ញុំលើសដែល
ឲ្យត្រៀបរបស់ទាំងពួង ខ្ញុំក៏មិនមានរត្នអ្វីឲ្យតបស្នងសងគុណ
អ្នកទេ លីស្តុកតបថា ដែលខ្ញុំយកសេះមានជួរជើងខ្លាំងពូកែមកជូនអ្នក
ទាំងនេះ ខ្ញុំបានគិតប្រាថ្នាយករបស់ជាសំណងសងវិញក៏ទេសោះ
ចំពោះតែថា អ្នកជាជាតិទាហានមានចិត្តសុចរិតទៀងត្រង់ប្រើនឹងធ្វើ
ការយកអាសាផែនដី ទើបខ្ញុំនាំសេះនេះមកជូន ។

ទើបលីប៉ោឲ្យរៀបចំ លៀងពោជនាហារ រណៈកាលលីស្តុក
កំពុងសេពស្រា ក៏មានពាក្យលីប៉ោថា លោកជំនោះតម្រូវនៅទី
កន្លែងណា អាណិតនាំខ្ញុំទៅជំនាប់ ដើម្បីឲ្យលោកស្គាល់ជួបមាន
ផង លីប៉ោតបថា អ្នកនៅឯណាមិនដឹងជាបិតាខ្ញុំអនុញ្ញាតឲ្យហើយ

(មានត)

មដ្ឋកុណ្ឌលីជិនាង

# ព្រះមហាកែវ · ណាគ្រី សុវិឌ្ឍនោ

( តមកចប់ )

ជ្រះថ្លាក្នុងព្រះអង្គ　　កាលស្តេចទ្រង់បិណ្ឌបាត
ពេលនោះខ្ញុំអាពាធ　　បានឃើញហើយចិត្តជ្រះថ្លា ។
កាលផុតលេតញាណ　　ខ្ញុំក៏បានទៅកើតជា
ទេវតារូបសោភា　　ទាំងបរិពារមាសពិមាន ។

មហាជនទាំងឡាយបាននាំគ្នាមើលមដ្ឋកុណ្ឌលីទេវបុត្រ ឃើញព្យាស់ឧនក្លែង ហើយមានចិត្តត្រេកអរសោទរ នាំគ្នានិយាយសរសើរថា « នែគ្នាយើងអើយ! គុណព្រះពុទ្ធអស្ចារ្យពេកណាស់, មើលហ្ន៎! កូនអទិន្នបុព្វកព្រាហ្មណ៍ គ្មានបានធ្វើបុណ្យទានអ្វីបន្តិចសោះទេ គ្រាន់តែធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសាស្តាប៉ុណ្ណោះ ក៏បាននូវសម្បត្តិដ៏សម្បើមយ៉ាងនេះ » ។

ព្រះមុនិន្ទលោកាចារ្យជាម្ចាស់ ទ្រង់ត្រាស់និពន្ធព្រះគាថាដូច្នេះថា ៖

មនោបុព្វង្គមា ធម្មា　មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន　ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ　ឆាយាវ អនុបាយិនី ។

ពេកសិនធម៌ទាំងឡាយទាំងពួងពិត តែងមានចិត្តជាប្រធានជាប្រថម ចិត្តវិសេសចិត្តវិសាលចិត្តឧត្តម ចិត្តជាធំនាំឲ្យស្រេចគ្រប់នានា ៗ កាលបើជនមានបសន្នចិត្តជ្រះ- ថ្លាស្រស់ក្សេមត្របះល្អះសោភា នោះនឹងធ្វើអំពើណាការនានា ដោយកាយវាចាឬមាត់និយាយស្តី ៗ សេចក្តីសុខតែងប្រតិបត្តិឲ្យផល ដល់បុគ្គលអ្នកប្រព្រឹត្តសុចរិតបី ដូចស្រមោលតែងតាមខ្លួនកាយសរីរ៍ មានសេចក្តីឧបមេយ្យដូច្នោះឯង ៗ

លុះព្រះអង្គសំដែងព្រះធម៌ទេសនានេះចប់ ទេវតានិងមនុស្ស ទាំងឡាយចំនួនប្រាំបីម៉ឺនបួនពាន់ បានសម្រេចមគ្គនិងផល តាមសមគួរ ដល់អភិនិហារនិស្ស័យរបស់ខ្លួនរៀងខ្លួន ៗ ឯអទិន្នបុព្វព្រាហ្មណ៍នឹង មដ្ឋកុណ្ឌលីទេវបុត្ត បានលុះសោតាបត្តិផលដូចគ្នាទាំងពីរនាក់ ៗ ចាប់ ដើមអំពីថ្ងៃនោះមក អទិន្នបុព្វព្រាហ្មណ៍បានបរិច្ចាគទ្រព្យសម្បត្តិ ដែលមានទាំងអស់ប៉ុន្មាន ទុំសបំពោះពុទ្ធសាសនាតែម្យ៉ាង ៗ

## គតិរបស់រឿង

រឿងដែលដំណាលមកនេះ បានគតិដូចមានខសំដែងតទៅនេះ ៖

១ មច្ឆរិយៈ — សេចក្តីកំណាញ់ស្អាញ់សម្បត្តិខ្លួននេះ លោក ចាត់ជាកិលេសគ្រឿងសៅហ្មងចិត្តមួយយ៉ាង ដែលជំរុញសត្វមិនឲ្យលះ ធនធានឲ្យទៅជាទានកើត ព្រោះខ្លាចអស់រលស់ទៅនូវទ្រព្យសម្បត្តិ ម្ល៉ោះហើយក៏ទទួលបរិហារកេរ្តិ៍ពីគេនិន្ទា ដូចតាប្រសុកការពារទ្រព្យមិនឲ្យ

ពាបដៃទចំផងបានជួញប្ដូរឯង ៗ ពួកជនដែលមានសេចក្ដីកំណាញ់កើតក្នុងសន្តានហើយ កុំបាច់និយាយដល់ការបែកចាយចំណាយទ្រព្យជាប្រយោជន៍ដល់អ្នកដទៃឡើយ សូម្បីតែជាប្រយោជន៍ខ្លួនឯងកូនប្រពន្ធក៏មិនហ៊ានចាយវាយទេ ប្ដូចាយក៏ចាយដែរ តែមិនសមល្មមនឹងបុណ្យយសសក្ដិទ្រព្យធនដែលមានៈ គួរយ៉ាងដូចគ្រឿងសំលៀកបំពាក់គឺសំពត់ខោអាវសារ៉ុងនិងគ្រឿងសម្រាប់ដេកគឺមុងនិងខ្នើយភួយគ្រែជេត ព្រមទាំងគ្រឿងបរិភោគ។ បរិភោគនឹងថ្នាំកែរោគជាដើម សម្រាប់ខ្លួននិងកូនប្រពន្ធ របស់ទាំងផុតាលនេះ តាមពិត មនុស្សយើងត្រូវឲ្យមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ តាមសមគួរដល់ធនធានខ្លួន ឯមនុស្សមានសន្ដានជាមច្ឆរិយៈ សូម្បីប្រើប្រាស់ស្លៀកពាក់តណ្ហាប់តណ្ហោប តណ្ហោតកណ្ដាប រហ៊ុយហៃ រហែកមុខរហ្វះក្រោយ មិនសមរម្យដល់ខ្លួនអ្នកផង បរិភោគអាហារខេបខាប រលីបលោប ត្រដាបត្រដួសហួសហេតុ ស្អុំអត់ស្មុំឃ្លាន ប្រហែលនឹងមនុស្សទាល់ក្រដែលរស់នៅដោយសារសូមទានគេ បើមានអាពាធកើតឡើង មិនហ៊ានទិញថ្នាំមកតាពាឬអញ្ជើញពេទ្យហ្មមកព្យាបាលឡើយ បើមានដំណើរទៅកាន់ទីឆ្ងាយ មិនហ៊ានជិះយានមានថ្លៃឈ្នួលទេ សូម្បីត្រាំដើរហាលថ្ងៃហាលភ្លៀងរលឹម ៗ បុគ្គលណាមានសេចក្ដីកំណាញ់កើតឡើងយ៉ាងនេះហើយ មាតាបិតាបងប្អូនកូនចៅញាតិមិត្រជិតខាង មិនអាចនឹងពឹងពាក់ពំនាក់អាស្រ័យ

បានឡើយ ។ មួយទៀត បើមានគ្រឿងទ្រព្យមកក្នុងផ្ទះ មនុស្សកំណាញ់មិនហ៊ានស៊ីផឹកការទឹកមុខស្រស់ស្រាយ ស្រកយ រាក់ទាក់ដោយពាក្យសំដីទៅរកភ្ញៀវទេ រមែងធ្វើមុខកញ្ចប់កញ្ចុង កំប៉ែកំប៉ូវ ក្រញេវក្រញូវ ដូចជាប្រទះនឹងភ្នាក់ដោយភ័យខ្លាចក្រែងគេមកសុំបុលទ្រព្យសម្បត្តិខ្លួន ៗ បើធ្វើយ៉ាងនេះ រឹងនឹងមានធនណាបានកើត អ្នកនោះឯងនឹងក្លាយទៅជាមនុស្សកំព្រាគ្មានមិត្តភក្តិគ្មាន ក្នុងពេលដែលមានកិច្ចធុរៈរវល់កើតឡើងប្រាកដជាគ្មានគេមកជួយជាគ្នាឡើយ ។ សេចក្តីនេះសមដូចសុភាសិតក្នុងគម្ពីរលោកនីតិថា ៚

ធាតំ សិនេហាកេសដ្ឋំ មច្ចោ ទោសទោសធំ

ធាតំ យសស្ស កេសដ្ឋំ មច្ចោ កាយ្យហោសធំ

ទានជាថ្នាំនាំកើតក្តីស្នេហា កំណាញ់ជាឱសថនៃទោសទុក្ខ

ទានជាថ្នាំយសស័ក្តិបរិវារសុខ កំណាញ់ទុកជាថ្នាំនាំកំព្រា ។

មួយទៀត ជនណាមានទ្រព្យសម្បត្តិហើយកំណាញ់ស្វិតស្វាញមិនចាយវាយទំនុកបំរុងខ្លួន · កូន · ប្រពន្ធ · ញាតិមិត្តទេ ទ្រព្យសម្បត្តិនៃជននោះចាត់ជារបស់ឥតប្រយោជន៍ ឥតអំពើ គ្មានខ្លឹមសារ មិនបានការស៊ីចាំនឹងអស់ ។ ចំណែកសប្បុរសប្រកបដោយចិត្តសទ្ធា រមែងថែងថែទ្រព្យសម្បត្តិដែលខ្លួនប្រឹងស្វះស្វែងរកបានមកនោះ ឲ្យជារបស់មានប្រយោជន៍ ៤ យ៉ាងគឺ ៚

១ ការសម្រាប់បំពេញមុខ - មាតាបិតា - បុត្រភរិយា - ទាសកម្មករ, ១ ការសម្រាប់សង្គ្រោះពួកញាតិមិត្ត ១ ការសម្រាប់ការពារសេចក្ដីអន្តរាយដែលកើតអំពីហេតុផ្សេងៗ ១ ការសម្រាប់ធ្វើពលិកម្ម ៥ យ៉ាង ១ ការទៀតសម្រាប់បរិច្ចាគសង្គ្រោះដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តត្រឹមត្រូវ ។

ព្រោះហេតុនោះបានជាមានសុភាសិតថា ៖

ធនំ អប្បម្បិ សាធូនំ ក្សេប ភវតិ និស្សយោ
ពហុមបិ អសាធូនំ ន ច ភវតិ អណ្ណវេ ។

ទ្រព្យសប្បុរសទោះតិចតួច បានជាប្រយោជន៍ជនឯនា
ដូចទឹកអណ្ដូងសេសាបថ្លា អស់មហាជនផឹកផងអាស្រ័យ ។
ទ្រព្យអសប្បុរសទោះមានច្រើន ពុំបានចំរើនអ្នកដទៃ
ដូចទឹកសមុទ្រទានសៅប្រៃ មនុស្សផឹកអាស្រ័យផឹកពុំបាន ។

វិធីចាយទ្រព្យដែលចែងចែកជាប្រភេទ ៤ ប្រការ ដូចមានខាងលើនេះហៅថាគាត់ជា "គម្រាចាយទ្រព្យ" ជនដែលចាយទ្រព្យត្រឹមត្រូវតាមគម្រានេះ រមែងកើតសួស្ដីសេចក្ដីចំរើនក្នុងលោកទាំងពីរគឺ លោកនេះនិងលោកខាងមុខ ដោយពិត ចំណែកជនអ្នកស៊ីគក់ណាញ់ទ្រព្យ មិនប្រកបការប្រើប្រាស់តាមគម្រានេះទេ រមែងដល់សេចក្ដីទុក្ខ មានការ

ចិត្តវិបរិតខ្វល់ក្បាល ឬអាចបណ្ដាលទៅជាឆ្កួតលីលា ស្ទើរក៏សឹងមាន ទុកជាទំយំស្រែកយ៉ាងណា ក៏អ្នកដែលស្លាប់ទៅឥតត្រឡប់វិលរស់វិញបានឡើយ ប្រហែលទីងតាយំតារបន់បានចើមសុខ ឬបន់បានសួងសេះ ឬក៏បង់បានគង់ពីជារថរបស់ព្រះអាទិត្យព្រះចន្ទ ដូច្នោះឯង ។ អាស្រ័យហេតុនេះ បានជាព្រះសព្វញ្ញុតញ្ញាណទ្រង់ត្រាស់ពន្យល់ក្នុងតិរោកុឌ្ឌសូត្រថា

ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា
ន តំ បេតានមត្ថាយ ឯវំ តិដ្ឋន្តិ ញាតយោ

ការយំឬការសោកសៅខ្សឹកខ្សួលដទៃ ៗ មិនមានប្រយោជន៍អ្វី ៗ ឡើយ ធ្វើយ៉ាងនេះ រកបានជាប្រយោជន៍ដល់បេតជនគ្មាន អ្នកដែលស្លាប់ទៅឥតបានដឹងបានឮការសោកសៅយ៉ាងនេះទេ ” ។

ហេតុនេះ សាធុជនគួរនៅនឹងគិតឲ្យឃើញថា «ការស្លាប់ ការបាត់បង់ព្រាត់ប្រាសឃ្លាតឃ្លាគ្នានេះ មិនមែនជាការចំឡែកប្លែកអ្វីឡើយ គឺជារបស់តែងមានធម្មតា សាសន៍ណា ជាតិណា ជនណា ដែលមានទ្រព្យសម្បត្តិសុខស្ដុកស្ដម្ភ ទានបានឋានៈយសស័ក្តិកាក់ចារខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ សាសន៍នោះ ជាតិនោះ ជននោះមុខជាចួបប្រទះប៉ះនឹងការព្រាត់ប្រាសដូចជាយើងដែរ ” ។ កាលបើប្រើពិចារណញ្ញាណយ៉ាងនេះ សេចក្ដីសោយសោកក៏នឹងអន់ថយចុះទៅជាលំដាប់ ។

៣- ធម្មជាតិសម្រាប់ពិចិត្រគិតតែគុំស្មៃលៃលងករកេសើរើ ឬផ្ទុំ ផ្គុំសន្សំប្រមុំប្រមូលនូវអារម្មណ៍ ធម្មជាតិនោះហៅថា "ចិត្ត" ៗ គឺឯចិត្តនេះ ជានាយហៅហ្វាយនៃកាយនឹងវាចា សម្រាប់បង្គាប់ប្រាប់ពន្យល់នូវកាយនឹងវាចា ឲ្យធ្វើនូវកិច្ចការនានាជាបុណ្យជាបាប បើជនណាមានចិត្តអាក្រក់លាមកហើយ ក៏ប្រើកាយឲ្យធ្វើអំពើអាក្រក់ ប្រើវាចាឲ្យនិយាយអាក្រក់ដែរ គឺនាំឲ្យវាត់កាប់សម្លាប់សំឡេះសត្វ លួចប្លន់ឆបោក កោតសម្ប័ត្តគេ ប្រព្រឹត្តកាមេសុមិច្ឆាចារ ពោលពាក្យកុហកអួតអាង ត្រគោះបោះបោកសើកសៀត ញុះញង់ ពេយពាយ គេវៀន រុតកួន ជេរ ជាម ឌឺដង តិះដៀល ត្អិះដៀល ថែប្ញូរ ជេរបញ្ចោរ ពោលបញ្ឆស តិចមតិកេះ ឈ្លោះប្រកែកប្រកាន់ ប្រច័ណ្ឌប្រទែង រកែរអ្ញរ រអ៊ូរទាំ រញ៉ាំរញ៉ៃ ពោលបង្កាច់ បាក់បុបអុបអាល ផល់គេឯង , ប្រព្រឹត្តផឹកទឹកស្រវឹងគឺទឹកត្នោតជូរទឹកស្រា ជក់បញ្ញាជក់អាភៀនជាដើម ;. អំពើបាបអកុសលទាំងនេះ ដែលគេធ្វើទៅកើត ក៏មកតែអំពីគំនិតគឺចិត្តជាមេនាំឲ្យធ្វើ ៗ ចំណែកដែលបុគ្គលកសាងសំណាងបុណ្យកុសលសុចរិតប្រព្រឹត្តធ្វើទានសីលភាវនា រហូតដល់លះកាមចូលកាន់ផ្នួសបួសជាស្រមណ៍ ប្រព្រឹត្តត្រឹមត្រូវតាមធម៌វិន័យ ដើរចូលព្រៃភ្នំធ្វើធុតង្គកម្មល ស៊ូទ្រាំហាលថ្ងៃហាលភ្លៀងស្ងួតសាច់ស្ងួតឈាម មិនខ្លាចស្លាប់ប៉ុណ្ណោះជាដើម ក៏មកតែអំពីចិត្តជួបគ្នា ៗ រួមគ្នារួបរួមសេចក្ដីឲ្យទៅថា « កាយវាចានឹង

ប្រព្រឹត្តធ្វើកិច្ចការជាបុណ្យជាបាប ក៏ព្រោះមានចិត្តជាមុនជាមេជាមគ្គ-នាយកបង្គាប់ឲ្យធ្វើ » ។ អំពើជាសុចរិតនិងទុច្ចរិតនេះឯងរមែងផិតជាប់តាមឲ្យផលជាសុខនិងជាទុក្ខដល់បុគ្គល ដូចស្រមោលអន្ទោលតាមប្រាណដូច្នោះឯង ។

ហេតុនេះ សាធុជនគួររក្សាការពារចិត្ត កុំឲ្យលិចចុះលង់ចូលចំណូលទៅក្នុងផ្លូវអាក្រក់គឺកុំឲ្យចិត្តគិតចង់បានទ្រព្យ អ្នកដទៃយកមកធ្វើជារបស់ខ្លួន, កុំឲ្យចិត្តគិតរកគុនព្យាបាទគេ , កុំឲ្យចិត្តគិតយល់ខុសជាត្រូវ ។ ក៏ចិត្តដែលប្រកបដោយលោភៈ ទោសៈ មោហៈ ទាំង ៣ យ៉ាងនេះណាមួយហើយឈ្មោះថាជាចិត្តមិនស្អាត ជាចិត្តគ្រោតគ្រាត ។ កាលបើចិត្តនៃបុគ្គលឯណាកខ្វក់ល្អក់មិនស្អាតដូច្នេះ ជាចិត្តសៅហ្មងហើយបុគ្គលនោះសលចំណាយខ្លួនទៅទីនៅកើតក្នុងទុគ្គតិភពជាប្រាកដ កាលបើចិត្តបរិសុទ្ធស្អាតប្រែះថ្លាវិញទីនៅកើតក្នុងសុគតិភព ដោយពិត ។

៤ - ព្រះមុនីនាថម្ចាស់ទ្រង់បានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ មានព្រះបញ្ញាញាណជ្រះយល់វែងឆ្ងាយ ទ្រង់ជ្រាបច្បាស់ហេតុផលបាបបុណ្យគុណទោសខុសត្រូវផ្ទៃកេស្មុគស្មាញ មានប្រយោជន៍ផងប្រយោជន៍គ្រប់បែបយ៉ាង ។ អំពើណាអាក្រក់លាមកជាកម្មបាប ទ្រង់លះបង់ដោយព្រះអង្គឯងព្រមទាំងសំដែងប្រាប់សត្វឲ្យលះបង់ផង អំពើណាជាបុណ្យគុណសុចរិត ព្រះអង្គទ្រង់សន្សំឲ្យកើតមាន ព្រមទាំង

- ២១៧ -

ប្រៀនប្រដៅសត្វឲ្យប្រតិបត្តិតាមផង ។ នេះជាគុណទី ១ របស់ព្រះពុទ្ធ ហៅថា បញ្ញាគុណ ។

ព្រះសម្ពុទ្ធមិនមែនមានត្រឹមតែបញ្ញាប៉ុណ្ណោះទេ ព្រះអង្គទ្រង់យកបញ្ញានោះមកសំរាប់កំចាត់កាត់ផ្តាច់អាសវក្កិលេសតណ្ហា ឲ្យអស់មិនមានសេសសល់សំណល់ក្នុងខន្ធសន្តាន ទ្រង់មានព្រះហឫទ័យបរិសុទ្ធផុតមន្ទិលសៅហ្មង ក្នុងហឫទ័យវិស័យចិត្តរបស់សាមញ្ញសត្វក្នុងត្រៃភព ព្រះអង្គមិនញាប់ញ័រមិនកក្រើករំភើបក្នុងព្រះហឫទ័យ ទ្រង់មានព្រះហឫទ័យនឹងធឹង ឥតរោះរោច មិនឃ្លេងឃ្លោង មិនបោងផត មិនខ្វល់ខ្វាយ ទៅតាមលោកធម៌ឡើយ ព្រះអង្គដល់នូវភាពជាអ្នកប្រសើរលើសត្វប្រមាណ ។ នេះជាគុណទី ២ របស់ព្រះពុទ្ធ ហៅថា វិសុទ្ធិគុណ ។

ព្រះអនន្តញាណទ្រង់មានបញ្ញានិងសេចក្តីបរិសុទ្ធនេះ ឈ្មោះថា ព្រះអង្គមានព្រះហឫទ័យកិច្ចធ្វើរួចស្រេចហើយ បើព្រះអង្គព្រងើយកន្តើយមិនខ្វល់ខ្វាយធ្វើអ្វីទៀត ហេតុដល់ព្រះអង្គទ្រង់បរិនិព្វានទៅវិញ ក៏បានដែរ តែព្រះអង្គនឹងធ្វើដូច្នោះមិនកើត ព្រោះព្រះអង្គមានព្រះមហាករុណាអាណិតអាសូរដល់មនុស្សសត្វទាំងពួងទៅ ដែលកំពុងនេះក្តៅដោយភ្លើងកិលេសគឺរាគៈ ទោសៈ មោហៈ និងភ្លើងទុក្ខគឺជាតិជរា ព្យាធិមរណៈជាប់ជំពាក់តាក់តែងជក់វិលវល់វែកវៃមកក្នុងកាលវែងឥតវេលាសង្សារ ត្រដាបត្រដួស ច្រួលច្រាស ផ្ទើមផ្ទឹម ផ្ទើលផ្ទោល កើតស្លាប់ៗកើត

ច្រើនកំណើតមិនកំណត់ក្នុងកប្ប ។ ព្រះជិនស្រីទ្រង់ក៏ផ្សាយព្រហ្ម-វិហារធម៌ដល់សព្វសត្វដោយឥតរើសមុខ ហើយទ្រង់ប្រកាសត្រាស់ទូន្មានប្រៀនប្រដៅសត្វ ដោយឥតគិតដល់ការនឿយហត់ឡើយ តាំងអំពីសម្ពោធិសម័យរហូតដល់ថ្ងៃបរិនិព្វានជាទីបំផុត នេះជាគុណទី ៣ នៃព្រះពុទ្ធហៅថា ករុណាគុណ ។

ព្រះសម្ពុទ្ធទ្រង់បរិបូណ៌ដោយបញ្ញាគុណ វិសុទ្ធិគុណនិងករុណាគុណដូចបានពណ៌នាមកនេះ បើជនណាមានចិត្តជ្រះថ្លានឹងព្រះអង្គ ហើយជននោះរមែងបានសេចក្ដីក្សេមក្សាន្តលោកនេះនិងលោកខាងមុខ គួយ៉ាងដូចមដ្ឋកុណ្ឌលីមាណព ដែលបានដំណាលរឿងមកហើយនោះឯង ។

នាមដើមខ្ញុំឈ្មោះអក្សរ "ណ" ស្រកាខ្យល់ត្រង់ស្រះអុ
រម្លងរួមគ្នាជា "ណាត្រី" ប៉ិនទៅទីវត្តទួលតាឯក ។
ខ្ញុំបានរៀបរៀងរឿងកាវែនេះ សូមលោកអ្នកចេះពិនិត្យថែក
ត្រង់ណាភ្លាំងភ្លាត់ខុសផ្ទុក ទុកចែកជូនញាតិជាតិខ្មែរ ។
សូមព្រះសទ្ធម្មបិតកតំមត់ សូមរដ្ឋធម្មញាណថាវរ:
សូមគុណជាវេឡុន: សមសក្ដិរងរឿងរុងរឿងអើយ ។

ចប់

# វិធីរក្សាចិត្តក្នុងបច្ចុប្បន្ន

## ( សុមង្គលវិលាសិនី )

## ឃុនបញ្ញានុរក្ស ប៊ូ-ប៉ូ រៀបរៀង

(តមកចប់)

ដោយឲ្យរបស់ទ្រព្យក្តី ដោយបង្ហាត់បង្រៀនចំណេះវិជ្ជាក្តី ហើយនឹងដល់សេចក្តីល្អរបស់មនុស្សដែលខ្លួនស្រឡាញ់ពេញចិត្ត មានមាតាបិតាគ្រូអាចារ្យជាដើមថា «លោកទាំងអស់នោះសុទ្ធតែបានធ្វើសេចក្តីល្អខ្ញុំមកពីមុនៗ ក្តីម្នាក់ៗ មិនមែនតិចទេ» ក្នុងវេលាដែលនឹកនោះត្រូវឲ្យរំពឹងនឹកដល់សេចក្តីល្អរបស់លោកទាំងអស់នោះឲ្យឃើញសព្វគ្រប់ទៅ ។

២ - ឲ្យនឹកដល់អំពើល្អដែលធ្វើឲ្យអ្នកដទៃបានល្អបានសុខថា «គេបានល្អបានសុខដោយគុណធម៌ណា គុណធម៌នោះយើងក៏មានដូចគេដែរ» ត្រង់ន័យនេះបានសេចក្តីថា យើងនឹកដល់អ្នកណាជាគំរូយ៉ាងដើម្បីបណ្តុះចិត្តយើងឲ្យរីកលយ យើងត្រូវពិចារណាមើលសេចក្តីល្អរបស់អ្នកនោះ ជាមុនហើយទើបពិចារណាមើលខ្លួនយើងថា «យើងគ្មានគុណធម៌បែបនោះដូចគេទេ» ឬមួយឃើញថា «យើងមានគុណធម៌បែបនោះដូចគេដែរ» ត្រូវឲ្យប្រៀបខ្លួនគេនឹងខ្លួនយើងជាខាងក្រោយ ។

៣ - ឲ្យនឹកដល់គុណរបស់ព្រះនិព្វានថា «ព្រះនិព្វានគ្មានសេចក្តីសោយសោក គ្មានសេចក្តីទុក្ខឡើយ មានតែសេចក្តីសុខមួយយ៉ាង»

ចំណែកអ្នកដែលមិនធ្លាប់បានស្តាប់មិនធ្លាប់បានដឹងរឿងព្រះនិព្វាន  នឹងឲ្យនឹកដូច្នោះមិនបានទេ  ត្រាន់តែឲ្យគេនឹកដល់គុណនៃសេចក្តីរីករាយសប្បាយចិត្តថា មានសេចក្តីសុខយ៉ាងណា ប៉ុណ្ណោះបានហើយ ព្រោះថាកាលបើគេនឹកយ៉ាងនេះហើយ គេគង់តែនឹងដឹងថា «សេចក្តីរីករាយសប្បាយចិត្តតែងធ្វើឲ្យបានសេចក្តីសុខជាច្រើន» ដ្បិតគេធ្លាប់ដឹងមកនឹងខ្លួនគេស្រាប់ហើយ ។

៤- កុំឲ្យសេពគប់នឹងមនុស្សខ្ជិលខ្ចក ឲ្យសេពគប់តែនឹងមនុស្សដែលមានចិត្តរីករាយក្លៀវក្លាជានិច្ច ព្រោះជានឹងធ្វើខ្លួនឲ្យរីករាយទៅតាមគេផង ។

៥ ឲ្យនឹកតែគ្រឿងរឿងដែលនាំឲ្យចិត្តសប្បាយរីករាយ ដែលខ្លួនធ្លាប់បានឮបានស្តាប់មកអំពីក្បួនច្បាប់ឬអំពីអ្នកដទៃ ឬក៏រឿងដែលធ្លាប់ធ្វើខ្លួនឲ្យមានចិត្តសប្បាយរីករាយមកពីដើម ទោះជាការលេងសើចក្តី ធ្វើការងារមែនទែនក្តី ពាក្យសំដីយ៉ាងណាក្តី ។

៦ ឲ្យបញ្ចូនចិត្តទៅរកសេចក្តីរីករាយ ពាល់តែចិត្តកើតសេចក្តីក្រេកក្រអាល គឺឲ្យហាត់ធ្វើជាអ្នកសប្បាយរីករាយ កុំឲ្យហាត់ធ្វើជាអ្នកខ្ជិលខ្ចក ។

កាលធ្វើតាមគោលទាំង ៦ ប្រការនេះបានហើយ សេចក្តីសោយសោក ឬ ក្តួចចិត្ត, ឈឺចិត្ត, អាក់អន់ចិត្តដែលកើតឡើងក្នុងវេលាឈឺចាប់

ឬនៅលាតាល់ក្រ, នៅក្រោកព្រឹកព្រាសចាកមនុស្សដែលខ្លួនស្រឡាញ់ ឬឃ្លាតចាកទីលំនៅទីនៃរបស់ខ្លួនត្រូវជាទីគាប់ចិត្ត គឺទីនៃទីសោយសោក ដែលគួរចិត្តទៅបាន ចិត្តត្រឡប់ជាសប្បាយរីករាយក្រៃក្រៃអាលយឿន ហើយបរិភោគអាហារក៏បាន ដេកក៏លក់ ធ្វើអ្វីក៏បានសម្រេចដូចប្រាថ្នា ។

## ៥ – វិធីកំចាត់សេចក្ដីមិនសប្បាយចិត្ត គឺចិត្តអផ្សុកមាន ៦ ប្រការគឺ:

១ - ឲ្យបរិភោគតែអាហារដែលត្រូវនឹងកម្លាំងរបស់ខ្លួន គឺអាហារ ដែលបរិភោគទៅហើយមិនធ្វើឲ្យហើមពោះ ឬឲ្យល្ហិតល្ហៃ, ឲ្យតឹងពោះផ្សេងៗ ។

២ - ឲ្យរើសរកអាកាសជាទីត្រូវនឹងនិស្ស័យចិត្តដើមរបស់ខ្លួន គឺថា បើខ្លួនត្រូវនឹងអាកាសក្ដៅខ្លាំងឬក្ដៅអ៊ុនៗ ឬក៏ត្រជាក់ ក៏ឲ្យរកទីដែលមាន អាកាសដូច្នោះជាទីស្រួលបពេកអារម្មណ៍ តែមានមនុស្សជាច្រើនត្រូវនឹង អាកាសត្រជាក់ ឬក្ដៅអ៊ុនៗ ឯអាកាសក្ដៅខ្លាំងទាល់តែស្អុះស្អាប់នោះមាន តែមនុស្សលោហិតគិចចើចត្រូវការ ។

៣ - ឲ្យរើសរកឥរិយាបថជាទីសប្បាយ គឺថាបើខ្លួនត្រូវនឹង ឥរិយាបថណាច្រើន ក៏ឲ្យប្រកាន់យកឥរិយាបថនោះជាប្រមាណ (ពាក្យ ថាឥរិយាបថ បានដល់ការដេក, ដើរ, ឈរ, អង្គុយ) ។

៤ - ឲ្យធ្វើខ្លួនជាកណ្ដាលៗ កុំបណ្ដោយចិត្តឲ្យរីករាយឬឲ្យអាក់អន់ក្នុងវេលាខ្លួនឯង ឬអ្នកដទៃមានទុក្ខភ័យអន្តរាយ ឬក៏បានសេចក្ដីសុខសេចក្ដីចំរើន ការដែលទំរង់ធ្វើចិត្តឲ្យជាកណ្ដាលៗដូច្នោះបាន ត្រូវឲ្យទុកពិចារណាដាក់កម្មជាធំថា "ព្រោះតែកម្មរបស់យើង, របស់គេ" ។ ត្រង់ពាក្យថា «កម្ម» នេះជាពាក្យកណ្ដាលៗ សំដៅយកទាំងការល្អ ទាំងការអាក្រក់ ។

៥ - កុំឲ្យសេពគប់នឹងមនុស្សដែលនៅមិនសុខ គឺមនុស្សដែលចូលចិត្តតែបៀតបៀនអ្នកដទៃ ចូលចិត្តតែធ្វើឲ្យគេក្ដៅក្រហាយ ឲ្យគេរំខាន ត្រូវសេពគប់នឹងមនុស្សដែលចូលចិត្តតែខាងសេចក្ដីស្ងប់ប៉ុណ្ណោះ ។

៦ - ត្រូវធ្វើចិត្តឲ្យធ្ងន់ទៅក្នុងផ្លូវស្ងប់កាយស្ងប់ចិត្ត គឺហាត់ទុកឲ្យទាល់តែកើតចិត្តស្ងប់ដែលចាត់ជាសេចក្ដីសប្បាយកាយសប្បាយចិត្ត ។

កាលបើធ្វើតាមគោលទាំង ៦ ប្រការនេះបានហើយ មុខជាបានទទួលសេចក្ដីសប្បាយកាយសប្បាយចិត្តជាប្រាកដ លែងក្ដៅក្រហាយដោយរឿងដែលកើតក្នុងចិត្តទៀយ ។

៦ – វិធីកំចាត់ចិត្តមិននឹង, មិនធ្ងន់ធ្ង មាន ៨ ប្រការគឺ ÷

១ ត្រូវរក្សាសេចក្ដីស្អាតទាំងខាងក្នុងខាងក្រៅ គឺត្រូវសំអាត

ឧនកាយ , សំលៀកបំពាក់ គ្រឿងប្រើប្រាស់និងទីលំនៅឲ្យស្អាតបាត ជានិច្ច ។

២ - ត្រូវធ្វើគុណធម៌ ៥ យ៉ាងគឺ សេចក្ដីជឿ ១ សេចក្ដីព្យាយាម ១ សេចក្ដីរឭក ១ សេចក្ដីតាំងចិត្ត ១ សេចក្ដីត្រិះរិះ ១ ឲ្យមានស្មើៗគ្នា កុំឲ្យតិចច្រើនជាងគ្នា ។

៣ - ត្រូវឲ្យធ្លាក់ក្នុងការកំណត់ចាំគ្រឿងសំគាល់របស់ផ្សេងៗ ដែលយើងបានជួបប្រទះ គឺជាកាលបើបានឃើញរបស់អ្វី ត្រូវតែពិចារណារករបស់ជាគ្រឿងសំគាល់ដែលអាចនឹងធ្វើឲ្យយើងសង្កេតចាំបានពិតប្រាកដកុំគ្រាន់តែមើលទទេៗ ។

៤ - ត្រូវបេះបណ្ដុះបណ្ដាលចិត្តឲ្យរឹងប៉ឹងខ្វែងខ្វែង ឲ្យរីករាយ នឹងត្រូវបេះប្រដៅចិត្តឲ្យល្អគឺកុំឲ្យចិត្តក្ដៅហួស កុំឲ្យចិត្តរីករាយហួស កុំឲ្យចិត្តអណ្ដែតអណ្ដូងរវើរវាយ ។ វិធីដែលនឹងធ្វើចិត្តឲ្យបានល្អដូច្នោះ ត្រូវឲ្យនឹកពិចារណាផលរបស់ដែលធ្វើចិត្តឲ្យទន់ខ្សោយ ឲ្យទុនថយ កាលបើនឹកឃើញរបស់ដូច្នោះហើយ ត្រូវលះបង់របស់នោះចោលចេញ ហើយឲ្យនឹកពិចារណាផលរបស់ដែលធ្វើចិត្តឲ្យរឹងប៉ឹងខ្វែងខ្វែង ដែលធ្វើចិត្តឲ្យរីករាយសប្បាយ ដែលធ្វើចិត្តមិនឲ្យរវើរវាយវិញ ។

៥ - បើដឹងថាចិត្តខ្លួនបាននឹងនួនខាងខ្លួនល្អហើយ ត្រូវឲ្យឈប់ស្ងៀមត្រឹមណោះ កុំបន្ទាបចិត្តចុះ កុំដំកើងចិត្តឲ្យខ្ពស់ឡើងទៀត

ត្រូវទប់ចិត្តឲ្យនៅនឹងតែត្រឹមប៉ុណ្ណោះ ទាល់តែចិត្តនោះជាប់ជានិស្ស័យ របស់ខ្លួនបានពិតប្រាកដ ។

៦ កុំឲ្យសេពគប់នឹងមនុស្សចិត្តសាវ៉ា, ចិត្តមិនទន់ខ្លួនមិនចុះចូល ត្រូវសេពគប់តែនឹងមនុស្សចិត្តទាបខ្លួនចុះចូល ជាអ្នកធ្វើអំពើអ្វីធ្វើមែនទែន មិនលេះលោះ មិនសាវ៉ា ។

៧ - ត្រូវគិតតែរបស់ដែលខ្លួនបានតាំងចិត្តធ្វើរួចមកហើយជាទីន ធ្វើហើយចំប្រឹងធ្វើរបស់នោះឲ្យទាល់តែបានសម្រេចតាមបំណងទីន ត្រូវធ្វើតែអំពើល្អ មិនត្រូវធ្វើអំពើអាក្រក់ឡើយ ។

៨ - ត្រូវធ្វើចិត្តឲ្យស្ងប់ទៅក្នុងផ្ទៃខាងខ្លួន ត្រូវស្រឡាញ់តែក្នុងផ្ទៃខាងខ្លួនជានិច្ច ។

កាលបើធ្វើតាមគោលទាំង ៨ ប្រការនេះបានហើយ គង់តែនឹង បានជាមនុស្សមានចិត្តមាំមួនធន់ធរមិនខាន ។

## ៣ - វិជ្ជាសម្រាប់កំចាត់ចិត្តមិនតាំងនៅជាកណ្តាល-មាន ៨ ប្រការ គឺ:

១ - ក្នុងវេលាខ្លួនឯងឬអ្នកដទៃបានទុក្ខក្តី បានសុខក្តី ត្រូវនឹកថា ព្រោះតែកម្មអាក្រក់ឬកម្មល្អរបស់យើងនិងរបស់គេ ឬមួយនឹកថា គ្មានអ្នកណាបានទុក្ខបានសុខឡើយ មានតែធាតុ ៤ ប៉ុណ្ណោះបានទុក្ខបានសុខ ។

២ - ត្រូវទុកថា គ្មានអ្នកណាជាម្ចាស់របស់អ្វីៗ ឡើយ របស់ទាំងអស់គ្រាន់តែជាគ្រឿងអាស្រ័យ មួយផងមួយកាលប៉ុណ្ណោះទេ ឬមួយទុកថា បណ្ដារបស់ទាំងអស់សុទ្ធតែជារបស់មាននៅមួយសំណើប៉ុណ្ណោះទេ មិនបាននៅឋិតថេរយឺនយូរឡើយ ។

៣ - កុំសេពគប់នឹងមនុស្សដែលជាប់ចិត្តនឹងអ្នកដទៃឬរបស់ដទៃទាល់តែចេញអាការប្រាកដមកខាងក្រៅ ដូចជាចូលចិត្តស្រឡាញ់អ្នកណាក៏ចេះតែវង្វេងទៅតាមអ្នកនោះដឹកនាំលែងដឹងខុសត្រូវ ឬមួយស្រឡាញ់របស់ណា កាត់ចិត្តពីរបស់នោះមិនដាច់ ។

៤ - ត្រូវសេពគប់តែនឹងមនុស្សជាកណ្ដាល ៗ ក្នុងអ្នកដទៃឬរបស់ដទៃ គឺជាមនុស្សមិនលំអៀងព្រោះសេចក្ដីស្រឡាញ់ឬស្អប់ជាដើម ។

៥ - ត្រូវបញ្ជូនចិត្តឲ្យស្ទុះឲ្យធ្ងន់ទៅក្នុងផ្លូវកណ្ដាល ៗ ជាដរាប ត្រូវទប់ផ្អាក់ចិត្ត ទាញចិត្តទៅរកតែផ្លូវកណ្ដាលជាដរាប ទាល់តែបានដឹងច្បាស់ថាចិត្តរបស់ខ្លួនតាំងនៅស៊ប់ក្នុងផ្លូវកណ្ដាលមែនទែនហើយ ។

កាលបើធ្វើតាមគោលទាំង ៥ ប្រការនេះបានហើយ មុខជានឹងកំចាត់ចិត្តលំអៀងឲ្យឃ្លាតចេញទៅបានជាមិនខាន ។

វិជ្ជាទាំង ៧ ប្រការដែលបានពណ៌នាមកហើយនេះ ជាវិជ្ជាមានគុណវិសេសដល់មនុស្សយ៉ាងធំក្រៃលែង ព្រោះថាបើអ្នកណាមិនធ្វើងក្លាំងក្លួប, មិនព្រងើយខ្ជៅ, មិនខ្ជិលច្រអូស, មិនតូចចិត្ត, មិនអផ្សុកចិត្ត,

មិនព្យាយាមលះលោះ, មិនលំអៀងជានិច្ចកាលហើយ អ្នកនោះនឹងធ្វើកិច្ចការអ្វីមួយនឹងគតហេតុអ្វី សូម្បីជាការក្រលំបាកឬជាហេតុជ្រាលជ្រៅកំបាំងទីទឹកចិត្តប្រាជ្ញាក៏អាចធ្វើឲ្យសម្រេចតាមប្រាថ្នាបាន ហេតុនេះ ត្រូវតែអ្នកប្រើគ្រឿងភ្ជាំងក្លួបប្រែន ។ល។ អ្នកមានចិត្តលំអៀង ទំប្រឹងប្រព្រឹត្តតាមវិជ្ជាទាំង ៧ ប្រការនេះឲ្យបាន ។

វិជ្ជារក្សាខ្លួន ៧ ប្រការ ចប់តែប៉ុណ្ណេះ

# ប្រវត្តិបុព្វចរិយា

របស់ព្រះមហា មាស – យូ ចៅអធិការវត្តក្បាលកោះអន្លង់ចិន

ព្រះតេជព្រះគុណព្រះមហា មាស-យូ មាតានាមចែម បិតានាមមាស លោកកើតនៅភូមិកណ្ដាលកោះ ឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្ដាល ក្នុងពុទ្ធសករាជ ២៤២៣ ឆ្នាំម្សាញ់ ត្រីស័ក ខែចេត្រ ថ្ងៃអង្គារ ។

កាលលោកនៅជាកុមារ អាយុបាន ៧ ឆ្នាំ មាតាបិតាបាននាំយកទៅឲ្យនៅសិក្សាអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូព្រះ វត្តកណ្ដាលកោះ ដកចដល់ចេះមើល ចេះសរសេរបានយ៉ាងស្ទាត់ ។ លុះអាយុ ១៤ ឆ្នាំ បានបព្វជ្ជាជាសាមណេរ នៅវត្តពោធិ៍បាន ៣ វស្សា ក៏លាចាកសិក្ខាបទមកជាឃរាវាស ប្រកបអាជីវកិច្ចតាមសម្មាអាជីវៈ បណ្ឌិតយូ មានកិរិយាសុភាពរាបសារ មានកាយវាចាទន់ភ្លន់ពីរោះផ្អែមល្ហែមចេះគួរសម ដឹងញាតិសន្ដានទៀងឈានចាស់ទុំព្រឹទ្ធាចារ្យណាស់ ពេញចិត្តគេទាំងការស្អាតជាទិច្ច ។

លុះអាយុបាន ២១ ឆ្នាំ ទើបភ្លូសមកឧបសម្បទាជាភិក្ខុ ក្នុងវត្តក្បាលកោះ លោកគ្រូសុវណ្ណបញ្ញោ នាម ស៊ូ ជាព្រះឧបជ្ឈាយ៍ លោកគ្រូធម្មក្ខេរ នាម គង់ ជាកម្មវាចា លោកគ្រូព្រហ្មជោតោ នាម អ៊ុំ ជាអនុសាវន បាននាមឆាយាថា សុវណ្ណជោតោ ក្នុងឆ្នាំជូត ត្រីស័ក ព.ស. ២៤៤៤ ខែទុតិយាសាឍ ថ្ងៃព្រហស្បតិ៍ ៣ កើត ។

លុះឧបសម្បទារួចហើយ ក្នុងវស្សាទី ១ ទី ២ បានរៀនបាដិមោក្ខបាលី ទាំងធម៌គាណាគារៈ ចេះចាំយ៉ាងស្ទាត់ជំនាញក្នុងការសូត្រ, ឧស្សាហ៍ធ្វើវត្តប្រតិបត្តិចំពោះគ្រូឧបជ្ឈាយ៍ដោយសេចក្តីគោរពយ៉ាងប្រពៃ ។

វស្សាទី ៣ ក៏លាព្រះឧបជ្ឈាយ៍ចេញទៅសំណាក់ព្រះធម្មដ្ឋានឯវត្តកៀនស្វាយក្រៅ ស្រុកកៀនស្វាយ ក្នុងសំណាក់លោកគ្រូនាមគង់ បាន ៣ វៃ ក៏ត្រឡប់មកកាន់វត្តដើមវិញ ។

វស្សាទី ៤ បានចេញទៅធ្វើបរិក្រសកម្មឯវត្តសាក់សំពៅ លុះរួចកិច្ចហើយ ទើបនិមន្តបន្ទូសទៅនៅរៀនព្រះត្រៃបិដកឯវត្តទ្រនង់ (ខាងទន្លេធំ) នៅរៀនក្នុងទីនោះបានមួយវស្សា ។

វស្សាទី ៥ ដល់វស្សាទី ១២ ត្រឡប់មកនៅសិក្សាឯវត្តកៃព្រះក្ញើងវិញ ក្នុងសំណាក់លោកគ្រូសាក្យវង្ស យូន បានរៀនគម្ពីរធម្មបទពីលោកគ្រូឈាបាវ្យព្រំ-គេក កាលនៅជាសង្ឃនៅឡើយ ហើយដែលទើបនិមន្តមកពីបាងកកថ្មីៗ ព្រះសពមានសេចក្តីព្យាយាមសង្វាតរៀនសូត្រណាស់ ទាំងមានសេចក្តីធ្ងន់ធ្ងរអត់ធន់ទ្រាំនឹងការលំបាកគ្រប់យ៉ាង ។ ដោយកំលាំងនៃការព្យាយាម នឹងសេចក្តីធន់ទ្រាំនេះហើយ ដែលធ្វើឲ្យលោកបានទៅជាអ្នកមានចំណេះវិជ្ជាដោយមុតមាំក្នុងពុទ្ធសាសនា ។ ក្នុងជំនាន់នោះព្រះករុណាជាម្ចាស់ជីវិតឯជាទុំហោជ្ឈ បានទ្រង់ព្រះរាជានុញ្ញាត បើកឲ្យព្រះសង្ឃដែលចេះព្រះត្រៃបិដកទាំងពុំទានចូលទៅប្រឡងដេញ

ប្រយោគនៅវិហារព្រះកែវមរកត ។ ពេលនោះព្រះសពក៏បានចុះឈ្មោះចូលទៅប្រឡងជាមួយនឹងព្រះសង្ឃឯទៀត ៗ ជាច្រើន ក៏បានជាប់ទីជាមហា ៤ ប្រយោគ ក្នុងឆ្នាំជូត ចត្វាស័ក ព.ស. ២៤៥៥ ថ្ងៃអាទិត្យ ៣ កើតខែផល្គុន ។ ព្រះករុណា ទ្រង់ព្រះរាជទានផ្ចិតមួយនឹងទេយ្យវត្ថុដទៃទៀតជាច្រើន នឹងសេចក្តីសរសើរអំពីការព្យាយាម ដែលលោកខំប្រឹងរៀនសូត្រដរាបដល់បានសម្រេចប្រយោគនេះ ។ រួចកិច្ចប្រឡងហើយ ក៏និមន្តត្រឡប់មកនៅវត្តក្បាលកោះវិញ ។

តាំងពីវស្សាទី ១៣ ឡើងទៅ ព្រះសពចាប់ផ្តើមបង្ហាត់បង្រៀនបាលីព្រះត្រៃបិដកដល់ភិក្ខុ-សាមណេរដែលនិមន្តមកអំពីទីជិតឆ្ងាយ ៗ ព្រមទាំងទេសនាដឹកនាំពន្យល់ឧបាសក-ឧបាសិកា ឲ្យបានចេះដឹងស្គាល់កិច្ចប្រតិបត្តិដ៏ត្រឹមត្រូវតាមផ្លូវពុទ្ធសាសនា កិត្តិសព្ទរបស់លោកក៏ល្បីល្បាញខ្ចរខ្ចាយសាយសុះទូទៅក្នុងទីទាំងពួង ។

ដល់មកក្នុងឆ្នាំរកា ត្រីស័ក ព.ស. ២៤៦៤ លោកគ្រូព្រហ្មជោតោ នាមគុំ ជាចៅអធិការវត្តក្បាលកោះមានអាពាធជាទម្ងន់ មិនយូរប៉ុន្មានក៏ចូលអនិច្ចធម្មទៅក្នុងថ្ងៃអង្គារ ១៤ កើតខែមិគសិរ វេលាម៉ោង ១០ ព្រឹក ។ ឯសពរបស់លោកគេដំកល់ទុកចំនួន ២ ខែ គឺដកចេញមកដល់ថ្ងៃ ១៤ កើតខែមាឃ ទើបបានធ្វើបុណ្យឈាបនកិច្ច ។

លំដាប់នោះ ព្រះតេជព្រះគុណព្រះមហាមាស - យូ បានទទួលងារជាចៅអធិការគេរៀនមក លោកខំយកព្រះទ័យទុកដាក់ក្នុងការរៀបចំវត្តអារាម ទាំងការកសាងសេនាសនៈផ្សេង ៗ គឺសាងព្រះវិហារក្នុងឆ្នាំរោងសំរិទ្ធិស័ក ព.ស. ២៤៧១ ព្រមទាំងសាលា តូច-ធំ, កុដិតូច-ធំ ធម្មន្ទីរហោត្រ័យ និងព្រះចេតិយសំរាប់បញ្ចុះធាតុគ្រូរបស់លោក, បានបង្កើតឲ្យមានសាលាបាលីរង ទំនុកបំរុងឲ្យមានគណាចារ្យមកបង្រៀនរាល់ឆ្នាំ ក្នុងមួយឆ្នាំ ៗ មានព្រះសង្ឃគាត់មកពីស្រុកជិតឆ្ងាយមករៀនសូត្រយ៉ាងតិចបំផុតត្រឹម ៥០ អង្គឡើងទៅ ; បានសុំរាជការឲ្យបង្កើតសាលាបឋមវិជ្ជា ជាទីបណ្តុះចំណេះវិជ្ជាដល់ពួកកូនចៅអ្នកស្រុកឲ្យបានចេះដឹងគ្រប់ ៗ គ្នា ។

នៅថ្ងៃអង្គារ ៣ កើត ខែកត្តិក ឆ្នាំមមែបញ្ចស័ក ព.ស. ២៤៨៦ ត្រូវនឹងថ្ងៃ ២ ខែកញ្ញា ព្រះសពបានទទួលគ្រឿងឥស្សរិយយសមេដាយប្រាក់ ដែលព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វរ្ម័ន ទ្រង់មានព្រះហឫទ័យប្រោសព្រះរាជទានទុកជាព្រះកេរ្តិ៍ ដោយសេចក្តីរាប់អានដ៏ស្មោះអស់ពីព្រះរាជហឫទ័យ ។

ព្រះតេជព្រះគុណព្រះសព លោកបួសជាសាមណេរបាន ៣ វស្សា, ជាភិក្ខុបាន ៤៨ វស្សា ។ តាំងដើមតាំងពីបួសមក លោកព្យាយាមធ្វើសេចក្តីប្រតិបត្តិជាប្រយោជន៍ដ៏ធំដល់ខ្លួនលោកផង ដល់ជនដទៃផង

ផល់ពុទ្ធសាសនាផង ៗ គឺដោយកំណាចសេចក្តីព្យាយាមរបស់លោក នេះហើយ ដែលនាំឲ្យទីវត្តទាំងមូល ទាំងមាតុភូមិរបស់លោកបែរមុខទៅរកសេចក្តីចំរើនដោយការបោះជំហានទាំងសេចក្តីប្រតិបត្តិធម៌វិន័យត្រឹមត្រូវតាមផ្លូវពុទ្ធសាសនា ទាំងចំរើនដោយវិសេសនាសនៈ កើតមានពាសពេញក្នុងវត្តសំរាប់ជាទីជ្រកកោននៃបព្វជិតទាំងឡាយ ដែលកាលពីដើមមានតែកុដិស្បូវពីរបីខ្នង ៗ ហើយមានសុទ្ធតែព្រៃស្បូវ ទាំងស្មៅព្រៅដុះខ្ទបខ្ទល ស្ងាត់ស្ងៀមយប់ឡើងគេឮសូរតែសត្វយំគួរឲ្យស្រណោះស្រណោច ៗ ក្រៅពីប្រាជ្ញាឈ្លាសវៃនិងសេចក្តីព្យាយាមពង្រីកសាសនាឲ្យបានរុងរឿងនេះ លោកនៅមានព្រះច័យសប្បុរសមួយយ៉ាងទៀតដែលមនុស្សទាំងអស់កម្រមាន ហើយដែលនាំឲ្យមានកិត្តិស័ព្ទថាជា «អ្នកប្រាជ្ញ» រឹតតែត្រាតដះឡើង ឯព្រះច័យសប្បុរសនោះគឺលោកមានមេត្តាចិត្តផ្សាយទៅកាន់បរិស័ទឥតរើសមុខ ៗ នៅវេលាដែលមានពុទ្ធដីកាទៅរកអ្នកណាមួយ លោកតែងមានពាក្យ យ៉ាងស្រទន់ផ្អែមល្ហែម ប្រកបដោយព្រះករុណាញញឹមយ៉ាងសុភាពសំឡឹងមើលដោយព្រះនេត្រដ៏ពេញទៅដោយមេត្តាទៅរកអ្នកនោះ មានចរិយាសណ្តាប់ធ្នាប់របៀបបែបបទស្រគត់ស្រគំសមរម្យជាសមណៈ អ្នកមានសទ្ធាចិត្តស្ងប់ស្ងាត់ជាប់ដោយសារប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុនោះហើយ បានជាពួកសប្បុរសទាំងឡាយ

គ្រាន់តែបានឃើញ - ជួបសន្ទនាជាមួយនឹងលោកតែម្តង  ក៏កើតសេចក្តីជ្រះថ្លាឡើង ។

ចំណេរចេរកាលតមក  ព្រះសពមានអាពាធក្តៅស្រៀវស្រាញអស់ចំនួនបួនដប់ថ្ងៃ ស្រាប់តែមកដល់ថ្ងៃ ៤ កើតខែទុតិយាសាឍ ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវជាអាយុគំរប់ ៦៧ ឆ្នាំ វេលានោះក៏បណ្តាលឲ្យខ្ទុរព្រះលោហិតចេញមកតាមព្រះទស្សន្តឲ្យស្រៀមពន់ពេក  បន្ទាប់ពីនោះមក  គាំងហើយធ្វើរធំឡើងបន្តិចម្តងៗ ដរាបរហូតដល់សព្វាង្គកាយទាំងមូល  ។  ពួកឧបាសក-ឧបាសិកានិងសិស្សានុសិស្ស  ទូទៅអស់ញាតិមិត្តក៏កើតភ័យព្រួយព្រាល់មហិមា  នាំគ្នាមកថែហឹងអឹងគាប់ពេញវត្តអារាម  ។

គ្រានោះ  ពេទ្យញ៉ាំងចំណាន១ ក៏បានមកព្យាបាលដោយម៉ឺងម៉ាត់  ប៉ុន្តែមិនអាចកាត់ពេលនោះបានឡើយ  ដរាបដល់ថ្ងៃពុធ ១១ កើតខែស្រាពណ៍  ឆ្នាំដដែលនេះទើបគេនាំគ្នានិមន្តលោកចុះចាកទៅឯមន្ទីរពេទ្យព្រះកេតុមាលា  ព្យាបាលពេលនោះអស់ ១ សប្តាហ៍  ក៏បានស្រាកស្រាន្តរម្ងាប់ព្រះអាពាធនោះទៅ  ហើយក៏ត្រឡប់មកវត្តវិញនៅថ្ងៃ ១៨ កើតខែកត្តិក  ។

បណ្តាំដែលព្រះពេទ្យបានផ្តាំឲ្យតមរៀវទាំងប៉ុន្មាន  មានតមម្ហូបចំណីបែបនិងគ្រឿងហិរក្តៅជាដើមនោះលោកពុំដែលហ៊ានប្រព្រឹត្តកន្លង

សោះឡើយ ទោះបីមានចំណង់ចង់បានយ៉ាងណាក៏ដោយ ក៏ស៊ូតែទំអត់សង្កត់ចំណង់ ព្រោះខ្លាចពេក នោះមានកំឡាំងរើឡើងវិញបាន ប៉ុន្តែទុកណាជាប្រយ័ត្នដល់ម៉្លេះក៏ដោយ កេតដែលមានឫទ្ធិយ៉ាងអស្ចារ្យនោះ គ្រាន់តែក្រាបសម្ពុំទៅចំនួនជា ១ ឆ្នាំប៉ុណ្ណោះ ក៏កំរើកឡើងជាថ្មីបានវិញ ព្រះសពក៏គោងតែនិមន្តទៅឯមន្ទីរពេទ្យម្ដងទៀត ។ ប៉ុន្តែម្ដងនេះ ពុំមានធូរថយសោះ អាពាធនុះក៏ឈានតែធ្ងន់ឡើងបន្តិចម្ដង ៗ ឥតស្រាកស្រាន្ត សូម្បីពេទ្យយ៉ាងចំណានមកពយាបាលយ៉ាងណា ក៏តែមិនកើត ទីបំផុតលោកក៏សន្លប់បាត់ស្មារតីឥតដឹងខ្លួន ប្រាណ សិស្សានុសិស្សដែលថែរក្សាអង្គលោក ដឹងច្បាស់ថាលោកធ្លាក់ក្នុងគណ្ដាប់ដៃនៃមច្ចុរាជហើយ ទើបនាំលោកត្រឡប់មកកាន់វត្តវិញ ។ នៅវេលាយប់ម៉ោង ១១ និង ១៥ នាទី ក្នុងថ្ងៃពុធ ១៣ កើតខែមិគសិរ ឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ ត្រូវនឹងថ្ងៃ ២៩ ខែធ្នូ ១៩៤៨ ត្រង់ជន្មាយុចូលក្នុងរវាង ៦៨ ឆ្នាំ ព្រះសពក៏ចូលនិព្វានចំពោះមុខសិស្សានុសិស្ស ទាំងគ្រហស្ថ បព្វជិតដែលមកចោមរោមជុំជិតដោយសេចក្ដីសោកស្ដាយយ៉ាងលើសលន់ពន់ប្រមាណ សឹងជាទុក្ខមុខក្រៀមក្រំ ជេជជ្រើមធំខ្សឹកខ្សួលគ្រប់គ្នា ស្ដាយអើយក្រៃលែងស្ដាយ ។

នាវេលានោះ គេត្រូវតែស័ព្ទជ័យលាន់ឡើងចេញពីតែងពេញទាំងមន្ទីរហោត្រៃ ជាកិច្ចជូនដំណើរក្នុងពេលទីបំផុតនៃជីវិតសន្តានរបស់លោក

បន្ទាប់ពីនោះមកសំឡេងគងនិងស្គរក៏លាន់ឮឡើងគឹកកងក្រែងក្នុងក្រើស្ងាត់ ជាសញ្ញាឲ្យដំណឹងដល់ជនទាំងឡាយឲ្យបានដឹងអំពីព្រឹត្តការណ៍នោះ ។ មរណសញ្ញានេះ ធ្វើឲ្យពួកសិស្សានុសិស្ស និងអស់ញាតិមិត្រទាំងពួងកើតសេចក្តីរំភើបក្តុកក្តួលរំជួលក្នុងចិត្តដោយសេចក្តីសោកស្តាយយ៉ាងក្រៃលែង ហាក់ដូចជាមានរបេះដូងធ្មើមប្រមាត់ជ្រុះធ្លាក់ពីក្នុងប្រាណ ។

នៅថ្ងៃព្រហស្បតិ៍ ១៤ រោច គឺជាថ្ងៃបន្ទាប់ពីថ្ងៃអនិច្ចធម្មនោះមក វេលារសៀលម៉ោង ៤ មានការជួបជុំ ដោយមហាជនទាំងបព្វជិត-គ្រហស្ថចាស់ក្មេងជាច្រើន ចូលមកគំនាប់ព្រះសពហើយនិមន្តឡើងកាន់ឡូត រួចផ្សារយ៉ាងធំ ទើបដាក់ក្នុងមឈូសដែលប្រដាប់ដោយគ្រឿងជាន់ដ៏មានក្បាច់រចនាគំនូរគូរក្រសព្រាលរម្លាលផ្ចិតផ្ចង់ ហើយទៅដំកល់ក្នុងសាលាធំយ៉ាងខ្ពស់ត្រដែត ។

ចាប់តាំងពីថ្ងៃនោះដរាបមក ពួកឧបាសក-ឧបាសិកាទាំងឡាយក៏នាំគ្នាមកធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសផលប្រគេនលោករាល់ថ្ងៃតាមវេន ។ ពិធីបុណ្យនោះគឺវេលាយប់និមន្តព្រះសង្ឃចំរើនបរិត្ត ជួនកាលមានទេសនាផង ព្រឹកឡើងអង្គាសភត្តាហារអស់ចំនួន ២ ខែ ១៤ ថ្ងៃ ។ លុះដល់ថ្ងៃអាទិត្យ ៣ កើតខែផល្គុន ឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១

ត្រូវនឹងថ្ងៃ ១៣ ខែមីនាឆ្នាំ ១៩៤៩ ទើបគេព្រមព្រៀងគ្នាធ្វើបុណ្យឈាបនកិច្ចបូជាសពលោក ដោយពិធីបុណ្យយ៉ាងធំ ឡូរីកគគឹកគគងអស់ ៣ ថ្ងៃ ២ យប់ ។

## ចប់ប្រវត្តិដោយសង្ខេប ។

ប្រវត្តិនេះ លោកគ្រូអាចារ្យខាម- ណាងហោ សុវណ្ណដោកោ ចហោបរិយត្តិវត្តឧវិដ្ឋា នៅវត្តក្បាលកោះ ឃុំកោះអន្លង់ចិន ស្រុកស្អាង ខែត្រកណ្ដាល បានរៀបរៀង ។

# សេចក្តីជូនដំណឹង

## រឿងបោះពុម្ពព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ

សាពត៌មានភាសាខ្មែរ ១ ឈ្មោះ «សំឡេងខ្មែរ» ចេញផ្សាយលើកដំបូង បានចោទសួរពុទ្ធសាសនបណ្ឌិត្យ អំពីរឿងបោះពុម្ពព្រះត្រៃបិដក ។ តែពាក្យចោទសួរនេះ គេអាចឆ្លើយដោយងាយ ដោយគ្រោះក្បាយពុំទេ ប្រសិនបើគេចង់ដឹងរឿងនេះបានអញ្ជើញទៅសួរដល់អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ឬអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។ ពាក្យចោទសួរនោះចង់ដឹងថា ៖

១) - ហេតុអ្វី ទើបគេឈប់បោះពុម្ពព្រះត្រៃបិដក?

២) - ដល់កាលណា ទើបគេចាប់បោះពុម្ពឡើងវិញ?

យើងគួរយល់ថា ការបោះពុម្ពសៀវភៅនោះ ត្រូវមានក្រដាសស្តើង, ក្រដាសក្រាស់ តួអក្សរសម្រាប់បោះពុម្ព និងប្រាក់កាសផង ។

ប្រសិនបើលោកណាមួយអ្នកធ្លាប់បានធ្វើការបោះពុម្ព នៅពេលដែលពុទ្ធសាសនបណ្ឌិត្យបង្អង់បោះពុម្ពព្រះត្រៃបិដកនោះ គង់នឹងជ្រាបថា ក្នុងរយៈវេលា ៣ ឆ្នាំមកនេះ គេបានជួបប្រទះនឹងសេចក្តីលំបាក យ៉ាងសំបើម ក្នុងការបោះពុម្ពគ្រប់មុខ ពីព្រោះគេឃើញមានតែក្រដាសយ៉ាងអាក្រក់ក្រៃលែង ហើយក្នុងពេលនោះ បើនៅស្រុករកមាសវិញ គេអាចរកបានដោយងាយជាងរកក្រដាសក្រាស់ៗ ( កាតុង ) ។ ប្រសិន

បើលោកអ្នកណាមួយដែលចង់ប្រាប់រឿងនេះ   បានអញ្ជើញទៅកាន់ពុទ្ធសាសនបណ្ឌិត្យប្រហែលយើងបានបង្ហាញក្រដាសស្រូតកាយ ដែលគ្រាតគគ្រើម   មានសំបុរខ្មៅ   ដែលយើងទ្រាំអត់មិនបានហើយនៅតែប្រើការសម្រាប់បោះពុម្ពៈសៀវភៅបាលី   និងទស្សនាវដ្ដីកម្ពុជសុរិយាអស់វេលា ៣ ឆ្នាំមកហើយ ។

យើងមិនអាចប្រើក្រដាសស្រូតកាយនេះ   សម្រាប់បោះពុម្ពព្រះត្រៃបិដកដែលសេសសល់មិនទាន់បានបោះពុម្ពនៅឡើយនេះទេ ពីព្រោះព្រះត្រៃបិដក ៣៥ ក្បាលដែលបានបោះពុម្ពរួចទៅហើយនោះ   សុទ្ធតែប្រើក្រដាសយ៉ាងប្រណីត   ហើយដាក់គ្របរឹងផង ។

យើងធ្លាប់បានសួរដោយចង់ដឹងថា   តើអស់លោកអ្នកជាវ   សុទ្ធចិត្តទទួលយកសៀវភៅដែលគេបានបោះពុម្ព   ដោយក្រដាសធុនអន់នេះឬទេ ។   គេឆ្លើយមកយើងថា   ទេ ។

ដល់ឥឡូវនេះ   យើងអាចរកក្រដាសប្រណីតនិងក្រដាសរឹងសម្រាប់ធ្វើគ្របបាន ។

ប៉ុន្តែ   យើងមានតែក្រដាសមួយមុខសម្រាប់បោះពុម្ពគ្រប់គ្រាន់ហើយឬ ?

យើងនៅត្រូវការប្រាក់នឹងអ្នកទទួលបោះពុម្ពផង ។ ឱ ! រឿងប្រាក់នេះ   យើងមានមិនគ្រប់គ្រាន់ទេ   ប៉ុន្តែយើងនឹងរកមធ្យោបាយណា

មួយ ដើម្បីជួយបំពេញការខ្វះខាតនេះតទៅ ។ ដូច្នេះ យើងសូមពន្យល់ ដោយច្បាស់លាស់អំពីរឿងនេះ ៖

មុនដំបូងយើងត្រូវដឹងថា ថវិការបស់ពុទ្ធសាសនបណ្ឌិត្យ មិនមាន ចំនួនប្រាក់ណាមួយ សម្រាប់បោះពុម្ពព្រះត្រៃបិដកទេ ។ ការបោះពុម្ព សៀវភៅដែលរួបរួមជាឈុតៗ នេះ ត្រូវមានដើមទុនធនធាន ១ ដោយឡែក គឺហិបប្រាក់ ១ ដាច់ដោយឡែក ដែលពួកអ្នកជាវត្រូវជួយទំនុកបំរុង ។ ប្រសិនបើ គេបើកសៀវភៅទី ១ ដែលបានបោះពុម្ពលើកដំបូង នោះ គេនឹងបានឃើញអក្សរនៅលើទំព័រម្ខាងជាភាសាបារាំង លើទំព័រម្ខាងទៀតជាភាសាខ្មែរថា « ដើមទុនដែលបំណាយបោះពុម្ពសៀវភៅព្រះត្រៃបិដក ភាគទី ១ នេះ គឺលោកប៉ូល–រ៉ាយណូត៍ រដ្ឋមន្ត្រីអាណានិគម បានធ្វើអំណោយផ្ទាល់ខ្លួន » ។

ដំឡៃបោះពុម្ពព្រះត្រៃបិដក ៣៨ ក្បាលតមកក្រោយទៀត សុទ្ធតែអ្នកជាវចេញថ្លៃទាំងអស់ ។ ក្នុងជាន់ដំបូងនោះគេបោះពុម្ព ១ លើកៗ ចំនួនពីរពាន់ក្បាល ក្នុង ១ ក្បាលៗ ដំឡៃដើមប្រហែល ១ រៀល ប៉ុណ្ណោះ ។ ដល់មកឥឡូវនេះ សម្រាប់ការបោះពុម្ពដូចគ្នានេះ ដំឡៃបោះពុម្ពក្នុង ១ ក្បាលៗ ឡើងដល់ ១០០ រៀល អញ្ចឹងមើលចុះថ្លៃគ្នាយ៉ាងណាទៅ ។ ដូច្នេះ យើងត្រូវមានប្រាក់ដល់ ២០០.០០០ រៀល

សម្រាប់ថ្លៃបោះពុម្ពព្រះត្រៃបិដក ១ ភាគ គិតពេលនេះ ដូច្នេះយើង មានប្រាក់សល់នៅគិតជាបត្រឹម ៧០.០០០ រៀលប៉ុណ្ណោះ ។ ហេតុនេះ ត្រូវរកមធ្យោបាយណាមួយជួយបំពេញការខ្វះខាតនេះ ដោយសុំឲ្យអ្នកជាវបង់ប្រាក់ថែម ឬសុំជំនួយពីរដ្ឋាភិបាល ។

ប៉ុន្តែនៅពេលនេះ យើងមិនមែនត្រូវការតែប្រាក់មួយយ៉ាងទេ គឺត្រូវមានរោងពុម្ពដែលអាចទទួលធ្វើការនេះបានផង ។ ដរាបមកដល់សព្វថ្ងៃនេះ រោងពុម្ពដទៃក្តី រោងពុម្ពព្រះរាជទ្រព្យក្តី មិនមានអក្សរគ្រប់គ្រាន់សម្រាប់ប្រើការបោះពុម្ពព្រះត្រៃបិដកទេ ដែលមានអក្សរមូលនៅទំព័រម្ខាង អក្សរជ្រៀងនៅទំព័រម្ខាង ។

កាលពីសម័យរដ្ឋការអាណាព្យាបាល រោងពុម្ពព្រះរាជទ្រព្យស្ទើរតែធ្វើការឲ្យពុទ្ធសាសនបណ្ឌិត្យទាំងស្រុង ប៉ុន្តែកាលពីពីរបីឆ្នាំមកនេះ រោងពុម្ពមានការរវល់ច្រើន ដោយទទួលធ្វើការឲ្យរដ្ឋាភិបាលខ្មែរ មិនអាចធ្វើការឲ្យពុទ្ធសាសនបណ្ឌិត្យតាមត្រូវការ ។ សៀវភៅដែលយើងសុំឲ្យបោះពុម្ពការយឺតយូរពន់ពេក ខ្លះដេកថ្ងៃដល់ពីរឆ្នាំហើយក៏នៅតែមិនទាន់បានចេញពីរោងពុម្ពក៏មាន ។

ហេតុដូច្នេះ ប្រសិនបើយើងមានប្រាក់ហើយនៅតែត្រូវយល់ថា កាលណារោងពុម្ពព្រះរាជទ្រព្យមានអក្សរ, ម៉ាស៊ីននិងអ្នកធ្វើការឲ្យបានគ្រប់គ្រាន់ ទើបអាចបង្ហើយការបោះពុម្ពព្រះត្រៃបិដកនេះបាន ។

ដូចគេបានឃើញស្រាប់ ការបោះពុម្ពព្រះត្រៃបិដកក្នុងពេលនេះ មិនមែនធ្វើបានដោយងាយស្រួល ដូចកាលមុនមានវិបត្តិក្នុងលោកនោះទេ បើមានតែត្រឹមឆន្ទៈល្អក៏ធ្វើការមិនកើត ។ ហើយមានសង្ឃឹមថា ប្រសិនបើលោកអ្នកណាមួយ ជាអ្នកស្នេហាជាតិ ជាអ្នកស្រឡាញ់ពុទ្ធសាសនា គួរតែធ្វើការឃោសនាយ៉ាងដាច់ប្រសើរមួយ ដើម្បីជួយឃើតយោងទឹកចិត្តទាយកឲ្យកើតសទ្ធាជ្រះថ្លា ព្រមទាំងឲ្យកើតឆន្ទៈល្អនៃអ្នកទទួលធ្វើការបោះពុម្ព ។

---